ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍

## លទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅអនុវត្តឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានកៅស៊ូ



ខែមករា ឆ្នាំ២០២៤

# មាតិកា


**១. សេចក្តីផ្តើម** ........ ១

១.១ ប្រវត្តិកៅស៊ូធម្មជាតិ ........ ១

១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ ........ ២

១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០២៣ ........ ២

១.៤ ថ្លៃកៅស៊ូធម្មជាតិនិងកត្តាមិនមែនមូលដ្ឋាន ........ ៣

១.៥ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០២៤ ........ ៤

**២. លទ្ធផលការងារសំខាន់ៗ ក្នុងឆ្នាំ២០២៣** ........ ៥

២.១ ការងាររដ្ឋបាលនិងនីតិកម្ម ........ ៥

២.១.១ ការងាររដ្ឋបាលនិងបុគ្គលិក ........ ៥

២.១.២ ការងារនីតិកម្ម ........ ៦

២.២ ការងារផែនការនិងហិរញ្ញវត្ថុ ........ ៦

២.២.១ ការងារផែនការ ........ ៦

២.២.២ ការងារហិរញ្ញវត្ថុ ........ ៧

២.៣ ការងារអភិវឌ្ឍន៍កៅស៊ូ ........ ៩

២.៣.១ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូ ........ ៩

២.៣.២ រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ ........ ១២

២.៣.៣ កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ ........ ១៣

២.៤ ការងារបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសិក្ខាសាលា ........ ១៤

២.៥ ការងារពិសោធន៍និងស្រាវជ្រាវ ........ ១៦

២.៦ ការងារសហប្រតិបត្តិការអន្តរជាតិ ........ ១៨

២.៦.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ........ ១៨

២.៦.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ........ ១៨

២.៦.៣ កិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន ........ ១៨

២.៦.៤ មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍ ........ ១៩

២.៦.៥ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ........ ១៩

២.៦.៦ អង្គការមូលនិធិសកលសម្រាប់ធម្មជាតិ ........ ១៩

២.៦.៧ អង្គការ OXFAM កម្ពុជា ........ ២០

២.៦.៨ អង្គការ NGO FORUM ............ ២០
២.៦.៩ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា (FAO) ............ ២១
២.៦.១០ សម្ព័ន្ធឧស្សាហកម្មកៅស៊ូវៀតណាម VRG ............ ២១
២.៦.១១ គម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ និងវៀតណាម ............ ២១
២.៦.១២ កិច្ចសហប្រតិបត្តិការជាមួយរោងចក្រកមន្តសាល ............ ២១
**៣. បញ្ហាប្រឈម** ............ ២២
**៤. សន្និដ្ឋាន** ............ ២៣
**៥. ទិសដៅឆ្នាំ២០២៤** ............ ២៣
**៦. ទិសដៅឆ្នាំ២០២៥** ............ ២៤
**៧. សំណូមពរ** ............ ២៥

# តារាង

តារាងទី១ ៖ ចំនួនមន្ត្រីរាជការតាមកម្រិតជំនាញ ............ ៥
តារាងទី២ ៖ លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពឆ្នាំ២០២៣ ............ ៦
តារាងទី៣ ៖ ស្ថិតិផ្ទៃដីកៅស៊ូក្នុងឆ្នាំ២០២៣ (ហិកតា) ............ ៩
តារាងទី៤ ៖ ស្ថានភាពនៃការប្រើប្រាស់កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ (នាក់) ............ ១៣
តារាងទី៥ ៖ កម្មវិធីសន្និសីទ កិច្ចប្រជុំ និងសន្និបាតរបស់សមាគម ANRPC ក្នុងឆ្នាំ២០២៣ ............ ១៨
តារាងទី៦ ៖ ទិសដៅសកម្មភាពឆ្នាំ២០២៤ ............ ២៣

# ដ្យាក្រាម

ដ្យាក្រាមទី១ ៖ ការប្រៀបធៀបថវិកាអនុម័តឆ្នាំ២០២២ និង២០២៣ ............ ៨
ដ្យាក្រាមទី២ ៖ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័ត ឆ្នាំ២០១៩-២០២៣ ............ ៩
ដ្យាក្រាមទី៣ ៖ ផ្ទៃដីចម្ការកៅស៊ូតាមបណ្តាខេត្ត (ហិកតា) ............ ១០
ដ្យាក្រាមទី៤ ៖ ទំហំប្រភេទផ្ទៃដីកៅស៊ូ ឆ្នាំ២០១៩-២០២៣ ............ ១០
ដ្យាក្រាមទី៥ ៖ ផ្ទៃដីកៅស៊ូយកផល ថែទាំ និងសរុប ឆ្នាំ២០១៩-២០២៣ ............ ១១
ដ្យាក្រាមទី៦ ៖ ផលិតផលនិងការនាំចេញកៅស៊ូធម្មជាតិ ឆ្នាំ២០១៩-២០២៣ ............ ១២
ដ្យាក្រាមទី៧ ៖ រោងចក្រ សិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ ២០១៩-២០២៣ ............ ១២
ដ្យាក្រាមទី៨ ៖ អត្រាគុណភាពកៅស៊ូល្អ (CSR L, CSR 5, CSR 10 និងRSS1) ឆ្នាំ២០១៩-២០២៣ ............ ១៣

# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ ៖ រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ ........ ២៦
ឧបសម្ព័ន្ធទី២ ៖ របាយការណ៍ប្រមូលចំណូលថវិការដ្ឋឆ្នាំ២០២៣ ........ ២៧
ឧបសម្ព័ន្ធទី៣ ៖ លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២៣ ........ ២៨
ឧបសម្ព័ន្ធទី៤ ៖ គោលដៅនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២៤ ........ ២៩
ឧបសម្ព័ន្ធទី៥ ៖ ស្ថិតិដំណាំកៅស៊ូកម្ពុជាឆ្នាំ២០២៣ ........ ៣០
ឧបសម្ព័ន្ធទី៦ ៖ ស្ថិតិផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(វសកក) ឆ្នាំ២០២៣ ........ ៣៤
ឧបសម្ព័ន្ធទី៧ ៖ តារាងផ្ទៃដីដាំដុះកៅស៊ូតាមឆ្នាំនីមួយៗគិតត្រឹមឆ្នាំ២០២៣ (ហិកតា) ........ ៣៥
ឧបសម្ព័ន្ធទី៨ ៖ ស្ថិតិផ្ទៃដីកៅស៊ូគ្រួសារឆ្នាំ២០២៣ ........ ៣៩
ឧបសម្ព័ន្ធទី៩ ៖ ស្ថិតិផ្ទៃដីកៅស៊ូលម្អិតតាមខេត្តឆ្នាំ២០២៣ ........ ៤០
ឧបសម្ព័ន្ធទី១០ ៖ តារាងសម្បទានដីសេដ្ឋកិច្ចបែងចែកតាមប្រភេទវិនិយោគិន ឆ្នាំ២០២៣ ........ ៤៥
ឧបសម្ព័ន្ធទី១១ ៖ ផ្ទៃដីកៅស៊ូធម្មជាតិ ឆ្នាំ២០១០-២០២៣ ........ ៤៦
ឧបសម្ព័ន្ធទី១២ ៖ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ ឆ្នាំ១៩៨០-២០២៣ ........ ៤៧
ឧបសម្ព័ន្ធទី១៣ ៖ ផ្ទៃដី ផលិតកម្ម នីហរណកម្មកៅស៊ូ និងការប្រើប្រាស់កៅស៊ូក្នុងស្រុកប្រចាំឆ្នាំ២០២៣ ........ ៤៨
ឧបសម្ព័ន្ធទី១៤ ៖ ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ ឆ្នាំ២០១០-២០២៣ ........ ៤៩
ឧបសម្ព័ន្ធទី១៥ ៖ ស្ថិតិរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូនៅក្នុងឆ្នាំ២០២៣ ........ ៥០


# រូបថត


រូបថតស្តីពីសកម្មភាពការងារថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ ........ ៥១
រូបថតស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម ........ ៥៤
រូបថតស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ ........ ៥៥
រូបថតស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ ........ ៥៦
រូបថតស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ ........ ៥៧
រូបថតស្តីពីសកម្មភាពនាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ ........ ៥៨
រូបថតស្តីពីសកម្មភាពការងាររបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ........ ៥៩

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅអនុវត្តឆ្នាំ២០២៤
# របស់អគ្គនាយកដ្ឋានកៅស៊ូ

## ១. សេចក្តីផ្តើម

### ១.១ ប្រវត្តិកៅស៊ូធម្មជាតិ

១- ដំណាំកៅស៊ូត្រូវបានដាំជាលើកដំបូងក្នុងប្រវត្តិសាស្រ្តកម្ពុជានាឆ្នាំ១៩១០ ដោយលោក **ប៊ូ យ៉ា** (Boulliard) ជនជាតិបារាំង នៅក្នុងស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្នខេត្តព្រះសីហនុ) លើផ្ទៃដីជាង ១៥០ហិកតា បន្ទាប់មកស្ថិតនៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានចម្ការកៅស៊ូមួយទៀតបានធ្វើការដាំដុះលើផ្ទៃដី ១២០ហិកតា និងបានធ្វើអាជីវកម្មលើផ្ទៃដីចំនួន ៨០ហិកតា។ មកដល់ឆ្នាំ១៩២១ ទើបចម្ការកៅស៊ូមានលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំ បានបង្កើតឡើងដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗចំនួន៥ នៅលើដីក្រហមបាសាល់នៅខេត្តកំពង់ចាម (ត្បូងឃ្មុំ) ខេត្តក្រចេះ និងខេត្តរតនគិរី លើផ្ទៃដីទំហំជាង៥០ ០០០ហិកតា។ រហូតមកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកផ្ទៃដីបានជាង៦៤ ០០០ហិកតា ក្នុងនោះផ្ទៃដីប្រមូលផលមានជាង៣៩ ០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូជាង៥០ ០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុក និងការនាំចេញ។ នៅជំនាន់នោះកៅស៊ូកម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ថាជាប្រទេសដែលមានចម្ការកៅស៊ូល្អ មានទិន្នផលខ្ពស់ និងផលិតផលកៅស៊ូប្រកបដោយគុណភាពល្អនៅក្នុងតំបន់អាស៊ី។

២- ចាប់តាំងពីឆ្នាំ១៩៧០មក ដោយសារសង្គ្រាមស៊ីវិលក្នុងស្រុក ជាពិសេសដំណាក់កាលចុងក្រោយស្ថិតក្រោមរបបគ្រប់គ្រងរបស់ពួកខ្មែរក្រហម រាល់ហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យត្រូវបានបំផ្លាញស្ទើរដល់ឫសគល់ រួមទាំងអាយុជីវិតប្រជាជនរាប់លាននាក់ត្រូវបានទទួលរងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ រួមទាំងស្ថានភាពចម្ការកៅស៊ូក៏ត្រូវបានខូចខាតស្ទើរទាំងស្រុង ហើយជីវិតកម្មករនិងប្រជាជនរាប់លាននាក់ត្រូវបានសម្លាប់។

៣- ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលបានរៀបចំដាក់ឱ្យដំណើរការស្តារនិងធ្វើអាជីវកម្មចម្ការកៅស៊ូចាស់ៗ ដែលនៅសេសសល់ឡើងវិញ រហូតមកដល់បច្ចុប្បន្ន។ ក្នុងគោលបំណងប្រែក្លាយកម្ពុជា ទៅជាប្រទេសផលិតករកៅស៊ូដ៏មានសក្តានុពលនៅក្នុងតំបន់ និងជាប្រទេសផ្គត់ផ្គង់ផលិតផលកៅស៊ូមួយចំណែកចូលទៅក្នុងទីផ្សារពិភពលោក រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីប្រកាស ស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជា ព្រមទាំងបានផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូដល់វិនិយោគិនក្នុងស្រុកនិងបរទេស។ តាំងពីដើមរៀងមក រហូតមកដល់បច្ចុប្បន្ននេះ ដំណាំកៅស៊ូនៅតែត្រូវបានគេប្រសិទ្ធនាមថាជា "**មាសស**" និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ខ្ពស់បន្ទាប់ពីផលិតផលស្រូវ។ ចាប់តាំងពីឆ្នាំ១៩៩៣មក រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់អតីតចម្ការកៅស៊ូរដ្ឋទាំង៧ ជាបន្តបន្ទាប់ពីស្វ័យាភិបាលសេដ្ឋកិច្ច មកជាសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ចនៅឆ្នាំ១៩៩៩ និងចុងក្រោយបានធ្វើអវិនិយោគឱ្យទៅផ្នែកឯកជនគ្រប់គ្រងទាំងស្រុងនៅចុងឆ្នាំ២០០៧-២០០៩។ ទន្ទឹមនឹងការធ្វើឯកជនភាវូបនីយកម្មអតីតចម្ការកៅស៊ូរដ្ឋ ថ្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិបានកើនឡើងខ្ពស់ជាបន្តបន្ទាប់ និងស្របពេលដែលរាជរដ្ឋាភិបាល

បានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់វិនិយោគិនក្នុងស្រុកនិងបរទេស ជំរុញឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាទាំងចម្ការកសិឧស្សាហកម្មនិងចម្ការកៅស៊ូគ្រួសារ បានចាប់ផ្តើមមានសន្ទុះកើនឡើងនិងមានការវិវត្តមួយប្រកបដោយថាមភាពទាំងនៅក្នុងផ្នែកដាំដុះ ការយកផល និងការនាំចេញផលិតផលកៅស៊ូផងដែរ។

## ១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ

៤- កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រដ៏សំខាន់មួយ ដែលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចជាតិ សង្គម និងបរិស្ថាន ជាពិសេសបានបង្កើតនិងបង្កើនប្រាក់ចំណូលដល់គ្រួសារកសិករ បង្កើតការងារនិងមុខរបរមានស្ថិរភាពនៅតាមតំបន់ជនបទនិងកាត់បន្ថយការធ្វើចំណាកស្រុក។ មិនតែប៉ុណ្ណោះ ផលិតផលកៅស៊ូធម្មជាតិគឺជាវត្ថុធាតុដើមមិនអាចខ្វះបាន ក្នុងវិស័យឧស្សាហកម្មកម្មន្តសាល ផលិតជាទំនិញរាប់រយមុខ សម្រាប់បម្រើតម្រូវការប្រើប្រាស់ប្រចាំថ្ងៃដូចជា៖ សំបកកង់យានយន្ត សម្ភារក្នុងលំនៅដ្ឋាន ក្នុងផ្នែកវេជ្ជសាស្ត្រដូចជាស្រោមដៃពេទ្យ ស្រោមអនាម័យ ។ល។និង។ល។ និងប្រើជាកំណាល់ទម្រសំណង់អគារ និងស្ពានធំៗ ទប់ទល់ការដួលរលំដោយសាររញ្ជួយផែនដី និងសម្រាប់លាយជាមួយល្បាយអាល់ស្វាតចាក់ក្រាលផ្លូវថ្នល់។ លើសពីនេះ បន្ទាប់ពីអស់ប្រសិទ្ធភាពសេដ្ឋកិច្ច កៅស៊ូធម្មជាតិបានផ្តល់ឈើសម្រាប់ប្រើប្រាស់ជាសំណង់ ឈើតន្ទះ ផលិតជាគ្រឿងសង្ហារឹម និងបានរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះ បង្កើតគម្របបៃតងឡើងវិញ ជួយថែរក្សាលំនឹងបរិស្ថាន កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមរបស់ពិភពលោកក្នុងពេលបច្ចុប្បន្ននិងទៅអនាគត។

## ១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០២៣

៥- ផលិតកម្មកៅស៊ូធម្មជាតិពិភពលោកបានធ្លាក់ចុះក្នុងអត្រាប្រចាំឆ្នាំ២,៤% ក្នុងអំឡុងពេល១០ខែដំបូងនៃឆ្នាំ២០២៣ (ចាប់ពីខែមករាដល់ខែតុលា)។ ដោយឡែកនៅរយៈពេលពេញមួយឆ្នាំ២០២៣ ផលិតកម្មកៅស៊ូធម្មជាតិត្រូវបានរំពឹងថានឹងធ្លាក់ចុះ១,៩% គឺនៅត្រឹមចំនួន១៤,៣៤០លានតោន បើធៀបនឹងឆ្នាំ២០២២ (Tyre Trends, ២០២៣)។

៦- ការប្រើប្រាស់កៅស៊ូធម្មជាតិពិភពលោកបានធ្លាក់ចុះក្នុងអត្រាប្រចាំឆ្នាំ២,២% មកត្រឹមចំនួន១២,៣៨៧លានតោន ក្នុងអំឡុងពេល១០ខែដំបូងក្នុងឆ្នាំ២០២៣ (ចាប់ពីខែមករាដល់ខែតុលា)។ តាមការរំពឹងទុក ការប្រើប្រាស់ពេញមួយឆ្នាំ២០២៣ នឹងធ្លាក់ចុះ១,៦% គឺនៅត្រឹមចំនួន១៤,៩២០លានតោន បើធៀបនឹងឆ្នាំ២០២២ (Tyre Trends, ២០២៣)។

៧- ប្រទេសឥណ្ឌាបានកាត់បន្ថយការនាំចូលកៅស៊ូធម្មជាតិរបស់ខ្លួនមកនៅត្រឹម៧,៨% ដែលមានចំនួន៤៧ ០០០តោន។ តួលេខនេះស្របនឹងគោលដៅ កាត់បន្ថយការនាំចូល ដើម្បីបំពេញតម្រូវការក្នុងស្រុក ដែលបានបង្ហាញនៅក្នុងសន្ទស្សន៍អ្នកគ្រប់គ្រងការទិញ (PMI) (ANRPC, ២០២៣)។

៨- ប្រទេសឥណ្ឌូណេស៊ីនិងម៉ាឡេស៊ី រំពឹងថានឹងមានការធ្លាក់ចុះនៃការនាំចេញកៅស៊ូធម្មជាតិ ជាមួយនឹងការថយចុះ៥,៩% និង៣,៥% រៀងគ្នាក្នុងខែតុលា ដែលបណ្តាលមកពីការធ្លាក់ចុះសន្ទុះផលិតកម្មនៅក្នុងប្រទេសទាំងពីរ (ANRPC, ២០២៣)។

៩- សមាគមអ្នកផលិតសំបកកង់អឺរ៉ុប (ETRMA) រំពឹងថាការលក់សំបកកង់ក្នុងសហភាពអឺរ៉ុប អាចមានបញ្ហាប្រឈមនៅឆ្នាំនេះ ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក គួបផ្សំជាមួយនឹងការកើនឡើងនៃថ្លៃដើម និងការថយ

ចុះប្រាក់ចំណូលនៅក្នុងទីផ្សារសំបកកង់របស់សហភាពអឺរ៉ុប។ ជាងនេះទៅទៀត បទប្បញ្ញត្តិគ្មានការកាប់បំផ្លាញព្រៃឈើរបស់សហភាពអឺរ៉ុប អាចនាំឱ្យមានផលប៉ះពាល់ដល់ការនាំចេញកៅស៊ូធម្មជាតិទៅកាន់សហភាពអឺរ៉ុប (ANRPC, ២០២៣)។

## ១.៤ ថ្លៃកៅស៊ូធម្មជាតិនិងកត្តាមិនមែនមូលដ្ឋាន

១០- ថ្លៃប្រេងឆៅ Brent បានកើនឡើងលើសពី៩៥ដុល្លារអាម៉េរិកក្នុងមួយបារ៉ែល ដោយសារការកើនឡើងនៃតម្រូវការ និងក្តីព្រួយបារម្ភពីការបន្ថយការផ្គត់ផ្គង់ពីប្រទេសអារ៉ាប៊ីសាអូឌីតនិងរុស្ស៊ី។ ថ្លៃប្រេងឆៅ Brent មានថ្លៃជាមធ្យមជិត៩៤ដុល្លារអាម៉េរិកក្នុងមួយបារ៉ែល ដែលមានការកើនឡើង២១ភាគរយ បើធៀបនឹងខែសីហា ដែលមានត្រឹមតែ៧៧ដុល្លារក្នុងមួយបារ៉ែល។ នៅក្នុងខែតុលា ប្រេងឆៅ Brent មានថ្លៃជាមធ្យមរង្វង់៩១ដុល្លារក្នុងមួយបារ៉ែល ដែលបង្ហាញពីធ្លាក់ចុះ៣,១% ធៀបនឹងខែមុន។ តាមការព្យាកររបស់ស្ថាប័នព័ត៌មានថាមពលរបស់សហរដ្ឋអាម៉េរិក (EIA) នឹងមានការកាត់បន្ថយចំនួន០,២លានបារ៉ែលក្នុងមួយថ្ងៃនៅក្នុងស្តុកប្រេងក្នុងអំឡុងឆមាសទី២ ឆ្នាំ២០២៣ (ANRPC, ២០២៣)។

១១- រូបិយប័ណ្ណរបស់ប្រទេសថៃនិងម៉ាឡេស៊ី បានធ្លាក់ទាបប្រៀបធៀបនឹងប្រាក់ដុល្លារអាម៉េរិក ដោយសារការរងឥទ្ធិពលពីជំហរមិនច្បាស់លាស់របស់ Federal Reserve ដែលបានកំណត់អត្រាការប្រាក់របស់ខ្លួននៅកម្រិតខ្ពស់ជាងរូបិយប័ណ្ណនៃប្រទេសទាំងពីរ។ ប្រទេសហ្វីលីពីននិងឥណ្ឌូនេស៊ី បានខិតខំប្រឹងប្រែងដំឡើងអត្រាការប្រាក់របស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងអតិផរណា និងការពាររូបិយប័ណ្ណរបស់ខ្លួនធៀបនឹងប្រាក់ដុល្លារអាម៉េរិក។ (ANRPC, ២០២៣)។

១២- ការទិញលក់កៅស៊ូតាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃ ទីផ្សារហ៊ុនអូសាកា និងទីផ្សារហ៊ុនសិង្ហបុរី បានបង្ហាញពីការកើនឡើងនៅខែកញ្ញានិងខែតុលា។ ថ្លៃទូទាត់ជាមធ្យមប្រចាំថ្ងៃនៃកិច្ចសន្យាលក់នៅលើទីផ្សារហ៊ុនសៀងហៃ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺពី១២,២១៧យន់ក្នុងមួយតោន ក្នុងខែសីហា ដល់១៤,១៩៦យន់ក្នុងមួយតោន ក្នុងខែកញ្ញា។ និន្នាការនេះ បានបន្តរហូតដល់ខែតុលា ជាមួយនឹងថ្លៃជាមធ្យមនៃកិច្ចសន្យាលក់១៤,៤៨៦យន់ក្នុងមួយតោន(ANRPC, ២០២៣)។ ទីផ្សារកៅស៊ូតាមកិច្ចសន្យាមានភាពវិជ្ជមានលើទីផ្សារហ៊ុនសៀងហៃ កើតចេញពីវិធានការជំរុញសេដ្ឋកិច្ចជាបន្តបន្ទាប់ ដែលរដ្ឋាភិបាលចិនបានអនុវត្ត។ សកម្មភាពថ្មីៗ របស់រដ្ឋាភិបាលចិន រួមទាំងការកាត់បន្ថយអត្រាការប្រាក់និងវិធានការគ្រប់គ្រងទុនលំហូរចេញបានរួមចំណែកដល់ការងើបឡើងវិញនៃទីផ្សារ។ ទន្ទឹមនឹងនេះ ប្រទេសថៃ មានភ្លៀងធ្លាក់ខ្លាំងខុសប្រក្រតី ដែលនាំឱ្យមានជំនន់ទឹកភ្លៀងរាលដាលនៅតាមតំបន់នានា នាំឱ្យមានការព្រួយបារម្ភពីការផ្គត់ផ្គង់ ដោយសារប្រទេសថៃគឺជាប្រទេសផលិតកៅស៊ូធម្មជាតិធំជាងគេ(ANRPC, ២០២៣)។

១៣- បន្ទាប់ពីការធ្លាក់ចុះជាបន្តបន្ទាប់ក្នុងរយៈពេល៣ខែជាប់គ្នា ថ្លៃកៅស៊ូមធ្យមប្រចាំថ្ងៃ បានងើបឡើងវិញក្នុងខែកញ្ញា ឆ្នាំ២០២៣។ នៅទីក្រុងគូឡាឡាំពួ ថ្លៃមធ្យមកៅស៊ូSMR-20 មានចំនួន១,៣៦ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម កើនឡើង៤,៦% ធៀបនឹងខែមុន។ ដូចគ្នានេះដែរ ថ្លៃមធ្យមកៅស៊ូSTR-20 នៅទីក្រុងបាងកកបានបន្តកើនឡើង៤,៤% ស្មើនឹង១,៤៣ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម(ANRPC, ២០២៣)។

១៤- និន្នាការថ្លៃកៅស៊ូជុំនៅតែបន្តកើនឡើងរហូតដល់ខែតុលា ថ្លៃមធ្យមកៅស៊ូSMR-20 នៅកូឡាឡាំពួរ បានឡើងដល់១,៩៥ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម ខណៈថ្លៃមធ្យមកៅស៊ូSTR-20 នៅទីផ្សារបាងកក បានឡើងដល់១,៥៤ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម (ANRPC, ២០២៣)។

១៥- ថ្លៃមធ្យមកៅស៊ូRSS-3 នៅទីក្រុងបាងកក បានកើនឡើងដល់១,៥៨ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម ស្មើនឹង ១,៩% នៅក្នុងខែកញ្ញា ឆ្នាំ២០២៣។ សន្ទុះជាវិជ្ជមាននេះ បានបន្តអូសបន្លាយដល់ខែតុលា ដែលថ្លៃបានកើនឡើងដល់១,៦៧ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម(ANRPC, ២០២៣)។

១៦- ផ្ទុយទៅវិញកៅស៊ូRSS-4 នៅទីផ្សារ Kottayam នៅប្រទេសឥណ្ឌា មានថ្លៃជាមធ្យម១,៧៧ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម បានធ្លាក់ចុះ០,០១ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម នៅក្នុងខែសីហានិងខែតុលា ឆ្នាំ២០២៣។ ដោយឡែកក្នុងខែតុលា ថ្លៃបានស្ទុះងើបឡើងវិញដល់១,៨០ដុល្លារអាម៉េរិកក្នុងមួយគីឡូក្រាម។ (ANRPC, ២០២៣)។

១៧- កត្តាខាងក្រៅដែលអាចមានឥទ្ធិពលលើទីផ្សារកៅស៊ូធម្មជាតិមានដូចខាងក្រោម៖

ក. ការកើនឡើងនៃភាពតានតឹងភូមិសាស្ត្រនយោបាយ ជាពិសេសនៅមជ្ឈិមបូព៌ារវាងប្រទេសអ៊ីស្រាអែល និងប៉ាឡេស្ទីន មានឥទ្ធិពលរាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក។

ខ. ភាពមិនប្រាកដប្រជាពីគោលនយោបាយរូបិយវត្ថុរបស់ប្រទេសផ្សេងទៀត ដែលទទួលរងឥទ្ធិពលពីស្ថានភាពក្នុងតំបន់និងលក្ខខណ្ឌសេដ្ឋកិច្ចពិសេស។

គ. ការសម្រេចចិត្តរបស់ Federal Reserve ក្នុងការផ្អាកអត្រាការប្រាក់ hawkish របស់ខ្លួន អាចផ្តល់ភាពធូរស្រាលខ្លះដល់វិស័យហិរញ្ញវត្ថុ ដែលមានភាពតានតឹងនិងទីផ្សារភាគហ៊ុនធ្លាក់ចុះ។

ឃ. ក្តីព្រួយបារម្ភលើទីផ្សារប្រេងឆៅ Brent អាចមានផលប៉ះពាល់លើទិន្នការនៃថ្លៃប្រេងឆៅនិងទីផ្សារទំនិញ។

ង. លក្ខខណ្ឌអាកាសធាតុមិនអំណោយផល អាចបណ្តាលឱ្យមានកាត់បន្ថយនៃការផ្គត់ផ្គង់កៅស៊ូធម្មជាតិ បើទោះជាផលិតកម្មកៅស៊ូធម្មជាតិឈានដល់កម្រិតខ្ពស់ក៏ដោយ(ANRPC, ខែតុលា ២០២៣)។

## ១.៥ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០២៤

១៨- សកម្មភាពសេដ្ឋកិច្ចត្រូវបានគេរំពឹងថានឹងស្ទុះងើបឡើងវិញនៅក្នុងតំបន់អាម៉េរិកនិងសហភាពអឺរ៉ុប នៅត្រីមាសទី១ ឆ្នាំ២០២៤ ដោយសារការចាប់ផ្តើមបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុដោយធនាគារកណ្តាលនៅតាមប្រទេសរៀងៗខ្លួន។ ធនាគារកណ្តាលអាម៉េរិកនិងធនាគារកណ្តាលអឺរ៉ុប ត្រូវបានគេរំពឹងថានឹងចាប់ផ្តើមកាត់បន្ថយអត្រាការប្រាក់របស់ពួកគេនៅចុងត្រីមាសទី២ ឆ្នាំ២០២៤ (Tyre Trends, ២០២៣)។

១៩- តាមការវិភាគរបស់ WhatNext Rubber ផលិតកម្មកៅស៊ូធម្មជាតិពិភពលោកក្នុងឆ្នាំ២០២៤ នឹងកើនឡើង ៤,២% គឺដល់ចំនួន១៤,៩៤១លានតោន។ ផ្អែកលើនិន្នាការសេដ្ឋកិច្ច ការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលរបស់ប្រទេសនីមួយៗ ការអភិវឌ្ឍក្នុងវិស័យដឹកជញ្ជូន និងឧស្សាហកម្មស្វ័យប្រវត្តិ ការប្រើប្រាស់កៅស៊ូធម្មជាតិពិភពលោកត្រូវបានគេព្យាករណ៍ថានឹងកើនឡើង៤,១% គឺដល់ចំនួន១៥,៥២៨លានតោន បើធៀបនឹងឆ្នាំ២០២៣ (Tyre Trends, ២០២៣)។

២០- ទីផ្សារកៅស៊ូសមាសរបស់ប្រទេសឥណ្ឌារំពឹងថា នឹងកើនឡើងបន្ថែមទៀតនៅប៉ុន្មានឆ្នាំខាងមុខ ដោយសារមានកំណើនផលិតកម្មសំបកកង់និងវិស័យរថយន្ត ហើយចំណូលនៃឧស្សាហកម្មសំបកកង់នឹងកើនឡើងដល់ ៣,៤% នៃផលិតផលក្នុងស្រុក (rubberworld, ២០២៣)។

២១- លោក Jom Jacob សហស្ថាបនិកក្រុមហ៊ុនវិភាគ WhatNext Rubber ដែលមានមូលដ្ឋាននៅប្រទេសឥណ្ឌា បានព្យាករណ៍ថាផលិតកម្មកៅស៊ូធម្មជាតិរបស់ប្រទេសចិន នឹងកើនដល់៩១០ ០០០តោន នៅឆ្នាំ២០៣០ ដោយសារផ្ទៃដីដាំកៅស៊ូថ្មីមានសក្តានុពលក្នុងការផ្តល់ជ័រកៅស៊ូខ្ពស់និងយូរអង្វែង (ANRPC, ២០២៣)។

## ២. លទ្ធផលការងារសំខាន់ៗ ក្នុងឆ្នាំ២០២៣

ក្នុងឆ្នាំ២០២៣ អគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់និងយ៉ាងសកម្ម ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## ២.១ ការងាររដ្ឋបាលនិងនីតិកម្ម

### ២.១.១ ការងាររដ្ឋបាលនិងបុគ្គលិក

២២- យោងតាមអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូ មានបេសកកម្មធានាការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យកៅស៊ូគ្រប់ផ្នែក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ ដើម្បីធានាដល់ការប្រកួតប្រជែងនៅលើទីផ្សារ តាមរយៈការផ្តល់សេវាស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ព្រមទាំងការអភិវឌ្ឍ និងការគ្រប់គ្រងខ្សែច្រវាក់ផលិតកម្ម អាជីវកម្មកែច្នៃសំដៅជំរុញពាណិជ្ជកម្មផលិតផលកៅស៊ូ។

២៣- អគ្គនាយកដ្ឋានកៅស៊ូ មានភារកិច្ចជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារជាអាទិ៍៖ រៀបចំនិងអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ ចក្ខុវិស័យ គោលដៅ បេសកកម្ម និងកម្មវិធីអភិវឌ្ឍន៍អនុវិស័យកៅស៊ូនៅកម្ពុជា សម្រាប់រយៈពេលមធ្យមនិងវែង កសាងមូលដ្ឋានគតិយុត្ត លិខិតបទដ្ឋានច្បាប់ ស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍកៅស៊ូ ធានារាល់ដំណើរការផ្សេងៗទៀត ដែលមានការពាក់ព័ន្ធដល់អនុវិស័យកៅស៊ូទូទាំងប្រទេស ព្រមទាំងភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

២៤- អគ្គនាយកដ្ឋានកៅស៊ូ មានរចនាសម្ព័ន្ធដឹកនាំ រួមមាន៖ ០៥នាយកដ្ឋានជំនាញ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន០១ ជាសេនាធិការ (ឧបសម្ព័ន្ធទី១) និងមានមន្ត្រីរាជការសរុបចំនួន១៦០នាក់ ក្នុងនោះស្រីមានចំនួន៤៧នាក់ ដែលកំពុងបម្រើការងារនៅតាមនាយកដ្ឋាននិងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលបែងចែកតាមកម្រិតជំនាញដូចមានក្នុងតារាងខាងក្រោម៖

តារាងទី១៖ ចំនួនមន្ត្រីរាជការតាមកម្រិតជំនាញ

| ល.រ | បរិយាយ | កម្រិតសញ្ញាបត្រ | | | | | |
|---|---|---|---|---|---|---|---|
| | | បណ្ឌិត | អនុបណ្ឌិត | បរិញ្ញាបត្រ | មធ្យម | ផ្សេងៗ | សរុប |
| ១ | ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ | ១ | ៤ | - | - | - | **៥** |
| ២ | នា.រដ្ឋបាល និងនីតិកម្ម | - | ៥ | ១០ | ២ | ១១ | **២៨** |
| ៣ | នា.អភិវឌ្ឍន៍កៅស៊ូ | ១ | ៥ | ១៦ | - | ៣ | **២៥** |
| ៤ | នា.ផែនការ ហិរញ្ញវត្ថុ និងស្ថិតិ | - | ៤ | ១៤ | - | ៣ | **២១** |
| ៥ | នា.កែច្នៃផលិតផលកៅស៊ូ | - | ៣ | ៩ | ៤ | ៣ | **១៩** |
| ៦ | នា.ទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ | - | ១ | ១០ | ៣ | ៥ | **១៩** |
| ៧ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ១ | ១០ | ២៨ | ២ | ២ | **៤៣** |
| **សរុប** | | **៣** | **៣២** | **៨៧** | **១១** | **២៧** | **១៦០** |

### ២.១.២ ការងារនីតិកម្ម

២៥- ក្នុងឆ្នាំ២០២៣ អគ្គនាយកដ្ឋានកៅស៊ូ៖

- បានរៀបចំផែនការកសាងលិខិតគតិយុត្ត ២០២៣-២០២៧
- បានប្រជុំពិនិត្យឡើងវិញលើប្រកាសលេខ០៤០ ប្រក.កសក. ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការស្នើសុំបង្កើតនិងដំណើរការរោងចក្រសិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូ ដើម្បីត្រៀមពិភាក្សាជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានរៀបចំសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីនៃការបង្កើតនិងការគ្រប់គ្រងថ្នាលបណ្តុះកូនកៅស៊ូ
- បានរៀបចំសេចក្តីណែនាំ ស្តីពីនីតិវិធីគណនារកភាគកៅស៊ូស្ងួត DRC ក្នុងទឹកជ័រកៅស៊ូធម្មជាតិ
- បានប្រជុំពិនិត្យបញ្ហាពាក់ព័ន្ធវិវាទដីធ្លីរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី
- បានចុះពិនិត្យនិងវាយតម្លៃសំណើសុំជួយអន្តរាគមន៍ពាក់ព័ន្ធនឹងផ្ទៃដីចំនួន១២ហិកតា ដែលអតីតនិយោជិតរបស់ចម្ការកៅស៊ូពាមជាំងចំនួន៥គ្រួសារ ដែលរំសាយពីការងារ ហើយទាមទារកាន់កាប់ដីរដ្ឋជាកម្មសិទ្ធិស្របច្បាប់ និង១គ្រួសារមិនព្រមចាកចេញទៅរស់នៅកន្លែងតាំងទីលំនៅថ្មី។

## ២.២ ការងារផែនការនិងហិរញ្ញវត្ថុ

### ២.២.១ ការងារផែនការ

២៦- ដើម្បីសម្រេចគោលបំណងនិងគោលដៅវិស័យកសិកម្ម ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ ពិសេសអនុវិស័យកៅស៊ូ អគ្គនាយកដ្ឋានកៅស៊ូ ដែលជាសេនាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាក្នុងកម្មវិធីទី០១ ដែលមានអនុកម្មវិធីចំនួន០១ និងចង្កោមសកម្មភាពចំនួន០៥។ សមិទ្ធផលផ្នែកកៅស៊ូ ដែលសម្រេចបានតាមបណ្តាចង្កោមសកម្មភាពនៃអនុកម្មវិធីនីមួយៗ របស់ថវិកាកម្មវិធីក្នុងឆ្នាំនេះ អាចវាយតម្លៃបានថាមានការរីកចម្រើនគួរជាទីមោទកភាព (តារាងទី២និងឧបសម្ព័ន្ធទី៣)។

តារាងទី២៖ លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពឆ្នាំ២០២៣

| ឈ្មោះចង្កោមសកម្មភាព | លទ្ធផល | | | |
|---|---|---|---|---|
| | សូចនាករ | ចំណុចដៅ | សម្រេចបាន | ភាគរយ |
| **អនុកម្មវិធី១.៥៖ ការជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិ** | *១.ផ្ទៃដីកៅស៊ូយកផល (ហិកតា)* | *៣១៩ ៧០០* | *៣២០ ១៨៤* | *១០០,១៥* |
| | *២.ផលិតផលកៅស៊ូ (តោន)* | *៣៩០ ០០០* | *៣៩១ ៨០០* | *១០០,៤៦* |
| | *៣.ការនាំចេញ (តោន)* | *៣៨៨ ០០០* | *៣៦៨ ០៤៨* | *៩៤,៨៦* |
| **ចង្កោមសកម្មភាព១.៥.១៖ ការជំរុញផលិតផលកៅស៊ូ** | ទិន្នផលកៅស៊ូកើនឡើង (គ.ក្រ/ហ.ត) | ១ ២២០ | ១ ២២៨ | ១០០,៦៦ |
| **ចង្កោមសកម្មភាព១.៥.២៖ ការកែច្នៃនិងការពង្រឹងគុណភាពកៅស៊ូ** | អត្រាគុណភាពកៅស៊ូល្អ (ភាគរយ) | ៧៩ | ៧៩,៣០ | ១០០,៣៨ |

| ឈ្មោះចង្កោមសកម្មភាព | លទ្ធផល | | | |
|---|---|---|---|---|
| | សូចនាករ | ចំណុចដៅ | សម្រេចបាន | ភាគរយ |
| **ចង្កោមសកម្មភាព១.៥.៣៖ ការពង្រឹងយន្តការទីផ្សារកៅស៊ូ** | អត្រាតម្លៃលក់ផលិតផលកៅស៊ូរបស់កសិករ/FOB (ភាគរយ) | ៧១ | ៧១ | ១០០ |
| **ចង្កោមសកម្មភាព១.៥.៤៖ ការរៀបចំការអនុវត្តផែនការ និងការគ្រប់គ្រងថវិកា** | អត្រាថវិកាត្រូវបានអនុវត្ត (ភាគរយ) | ៩៥ | ៩២,៨៦ | ៩៧,៧៥ |
| **ចង្កោមសកម្មភាព១.៥.៥៖ ការកសាងក្របខណ្ឌគតិយុត្តនិងអភិវឌ្ឍន៍ធនធានមនុស្ស** | ១.ចំនួនសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត (ច្បាប់) | ១ | ១ | ១០០ |
| | ២.ចំនួនប្រតិបត្តិករកៅស៊ូ (នាក់) | ១៥០ | ១៥០ | ១០០ |

២៧- អគ្គនាយកដ្ឋានកៅស៊ូបាន (១) រៀបចំគម្រោងផែនការថវិកាកម្មវិធីឆ្នាំ២០២៤ បានទាន់ពេលវេលា និងទទួលបានការអនុម័តយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអនុកម្មវិធីចំនួន០១ គាំទ្រដោយចង្កោមសកម្មភាពចំនួន០៥ (ឧបសម្ព័ន្ធទី៤) (២) ចេញលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារចំនួន០៣ទីតាំង និងបានចេញលិខិតអនុញ្ញាតបន្តសុពលភាពចំនួន០១ទីតាំង និង(៣) ចូលរួមសហការជាមួយគណៈប្រតិភូអធិការកិច្ចសវនកម្មផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈប្រតិភូអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ (ការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ) ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋ។

## ២.២.២ ការងារហិរញ្ញវត្ថុ

២៨- ការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានកៅស៊ូក្នុងឆ្នាំ២០២៣ អនុវត្តបានមានចំនួន១ ៧១៤ ៧៨២ ៥៤៣រៀល (៤១៧ ៣១០,០៥ដុល្លារអាម៉េរិក) មានការកើនឡើងចំនួន២០៣ ៣៨២ ៥៤៣រៀល ស្មើនឹង ១៣,៤៦% បើធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ មានចំនួន១ ៥១១ ៤០០ ០០០រៀល ក្នុងនោះរួមមាន ការជួលដីទំនេររបស់ក្រុមហ៊ុនអវិនិយោគចម្ការកៅស៊ូទាំង០៧ មានចំនួន១ ១៥៩ ៣៨២ ៤២៦រៀល (២៨៣ ៥៣៩ ដុល្លារអាម៉េរិក) និងការជួលដីមានអគាររបស់ក្រុមហ៊ុននីហាវ័ណ អាហារ័ណកៅស៊ូ និងចម្ការកៅស៊ូឡាបានសៀកមានចំនួន៥៥០ ៣៩៥ ៨២០រៀល (១៣៣ ២៨៧,៧៩ដុល្លារអាម៉េរិក) និងការពិន័យនិងការដាក់ទណ្ឌកម្មពិន័យជាប្រាក់យឺតយ៉ាវក្នុងការទូទាត់ថ្លៃឈ្នួលចម្ការកៅស៊ូស្នួល ឆ្នាំ២០២៣ មានចំនួន១ ៩៩៧ ៧៩៧រៀល (៤៨៣,២៦ដុល្លារអាម៉េរិក) និងការបង់សំណៃសចំណាយបៀវត្សឆ្នាំ២០២២ មានចំនួន៣ ០០៦ ៥០០រៀល។ ការកើនឡើងនេះ ដោយសារ (១)ចម្ការកៅស៊ូឡាបានសៀក មានការកើនឡើងផ្ទៃដីមានដើមកៅស៊ូយកផល និងបានកើនឡើងថ្លៃជ័រកៅស៊ូប្រចាំឆ្នាំ (២)ចម្ការកៅស៊ូស្នួល បានបង់ប្រាក់ពិន័យយឺតយ៉ាវក្នុងការទូទាត់ថ្លៃឈ្នួលឆ្នាំ២០២៣ និង(៣)ប្រាក់បង់សំណៃសចំណាយបៀវត្សឆ្នាំ២០២២ (ឧបសម្ព័ន្ធទី២)។

២៩- ការងារដែលបានអនុវត្តៈ

- បានរៀបចំគម្រោងចំណាយថវិកាកម្មវិធីនិងស្នើសុំគោលការណ៍ចំណាយថវិកាវេជ្ជទេយ្យបុរេប្រទាន
- បានរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងស្នើសុំគោលការណ៍ធានាចំណាយថវិកាលើការងារលទ្ធកម្មទូទៅ ប្រេងឥន្ធនៈ សម្ភារការិយាល័យ សង្ហារឹម ឧបករណ៍បច្ចេកទេស ជួសជុលរថយន្ត និងជួសជុលអាគារ ធ្វើការដេញថ្លៃ និងធ្វើការប្រគល់-ទទួល
- បានរៀបចំសក្ខីប័ត្របញ្ចប់លើការងារទូទាត់ថវិកាកម្មវិធីទាំង៤ជំពូក និង
- បានរៀបចំការចុះបញ្ជីសារពើភ័ណ្ឌកើន-ថយ ទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២៣។

៣០- ថវិកាអនុម័តឆ្នាំ២០២៣ មានចំនួន៣ ៩៦៨,២០លានរៀល ធៀបនឹង២០២២ មានចំនួន៣ ៥៥៨,២០លានរៀល គឺមានកើនឡើងចំនួន៤១០លានរៀល ស្មើនឹង១១,៥២%។ ជំពូក៦១ សេវាខាងក្រៅ បានកើនឡើងចំនួន១០១,១០លានរៀល ស្មើនឹង១៥,០៣% ជំពូក៦៤ បន្ទុកបុគ្គលិក បានកើនឡើងចំនួន៣០៧,៤០លានរៀល ស្មើនឹង១១,៩៧% ជំពូក៦៥ ឧបត្ថម្ភធននិងជំនួយសង្គម បានកើនឡើងចំនួន៤លានរៀល ស្មើនឹង ៩,៥២%។ ដោយឡែកជំពូក៦៣ ពន្ធនិងអាករ បានថយចុះចំនួន២,៥០លានរៀល ស្មើនឹង៥០% និងជំពូក៦០ ការទិញ គឺមិនមានការប្រែប្រួល (ដ្យាក្រាមទី១)។




ដ្យាក្រាមទី១៖ ការប្រៀបធៀបថវិកាអនុម័តឆ្នាំ២០២២ និង២០២៣

៣១- នៅក្នុងឆ្នាំ២០២៣ ការអនុវត្តចំណាយថវិកាសម្រេចបាន៣ ៦៨៥,០៤លានរៀល ស្មើនឹង៩២,៨៦% ធៀបទៅនឹងថវិកាអនុម័តដែលមានចំនួន៣ ៩៦៨,២០លានរៀល។ ក្នុងរយៈពេល៥ឆ្នាំ គិតពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ការអនុវត្តចំណាយថវិកា (មិនគិតបញ្ចូលថវិការបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) គឺមានការប្រែប្រួលឡើងចុះជាបន្តបន្ទាប់។ ដោយចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ ការអនុវត្តថវិកាមានការថយចុះក្នុងកម្រិតអត្រាប្រចាំឆ្នាំ១០,៣៥%។ ការថយចុះនេះ គឺដោយសារការរីករាលដាលនៃជំងឺកូវីត១៩ ដែលធ្វើឱ្យសកម្មភាពសំខាន់ៗមួយចំនួន មិនអាចអនុវត្តបានដោយពេញលេញ។ ដោយឡែកចាប់ពីឆ្នាំ២០២១-២០២៣ ដោយសារការរីករាលដាលនៃជំងឺកូវីត១៩ មានសភាពធូរស្រាល ការអនុវត្តចំណាយថវិកាមានការ

កើនឡើងក្នុងកម្រិតអត្រាប្រចាំឆ្នាំ៣,៤១%។ បើធៀបនឹងថវិកាអនុម័ត ក្នុងរយៈពេល៥ឆ្នាំ ការអនុវត្តថវិកាសម្រេចបានពី៨៣,៨៨% ទៅ១០១,៧៨% ធៀបនឹងថវិកាអនុម័ត (ដ្យាក្រាមទី២)។




ដ្យាក្រាមទី២៖ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័ត ឆ្នាំ២០១៩-២០២៣

## ២.៣ ការងារអភិវឌ្ឍន៍កៅស៊ូ

### ២.៣.១ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូ

៣២- នៅឆ្នាំ២០២៣នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន៤០៧ ១៧២ហិកតា បើធៀបទៅនឹងឆ្នាំ២០២២ ដែលមានចំនួន៤០៤ ៥៧៨ហិកតា គឺកើនចំនួន២ ៥៩៤ហិកតា ស្មើនឹង០,៦៤%។ ការកើនឡើងផ្ទៃដីនេះ ភាគច្រើននៅលើផ្ទៃដីចម្ការកៅស៊ូគ្រួសារ ចំណែកផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចថយចុះ ដោយក្រុមហ៊ុនមួយចំនួនបានផ្លាស់ប្តូរមុខដំណាំ ដោយសារលក្ខខណ្ឌដីមិនសមស្របនឹងដំណាំកៅស៊ូ និងដោយសារភ្លើងឆេះនៅរដូវប្រាំង។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា០២ផ្នែកគឺ៖ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (ផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន២២៦ ៨៤០ហិកតា ស្មើនឹង៥៦% និងកៅស៊ូគ្រួសារមានចំនួន១៨០ ៣៣២ហិកតា ស្មើនឹង៤៤% នៃផ្ទៃដីកៅស៊ូសរុប (តារាងទី៣ ដ្យាក្រាមទី៣ ដ្យាក្រាមទី៤ និងឧបសម្ព័ន្ធទី៥ ទី៦ ទី៧ ទី៨ ទី៩ ទី១០ ទី១១ និងទី១២)។

តារាងទី៣៖ ស្ថិតិផ្ទៃដីកៅស៊ូក្នុងឆ្នាំ២០២៣ (ហិកតា)

| ប្រភេទចម្ការកៅស៊ូ | កៅស៊ូយកផល | កៅស៊ូថែទាំ | សរុប | ភាគរយ |
|---|---|---|---|---|
| **១.ចម្ការកៅស៊ូកសិឧស្សាហកម្ម** | **១៦៤ ១៨៤** | **៦២ ៦៥៦** | **២២៦ ៨៤០** | **៥៦** |
| -អតីតចម្ការកៅស៊ូរដ្ឋនិងវ.ស.ក.ក. | ៣៣ ២៦០ | ១៣ ៤២២ | ៤៦ ៦៨២ | ១១ |
| -ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | ១៣០ ៩២៤ | ៤៩ ២៣៤ | ១៨០ ១៥៨ | ៤៤ |
| **២. ចម្ការកៅស៊ូគ្រួសារ** | **១៥៦ ០០០** | **២៤ ៣៣២** | **១៨០ ៣៣២** | **៤៤** |
| **សរុប** | **៣២០ ១៨៤** | **៨៦ ៩៨៨** | **៤០៧ ១៧២** | **១០០** |

*សម្គាល់៖ វ.ស.ក.ក.៖ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*




ដ្យាក្រាមទី៣៖ ផ្ទៃដីចម្ការកៅស៊ូតាមបណ្តាខេត្ត (ហិកតា)




ដ្យាក្រាមទី៤៖ ទំហំប្រភេទផ្ទៃដីកៅស៊ូ ឆ្នាំ២០១៩-២០២៣

៣៣- ឆ្នាំ២០២៣ ផ្ទៃដីកៅស៊ូយកផលអនុវត្តបានចំនួន៣២០ ១៨៤ហិកតា ធៀបនឹងឆ្នាំ២០២២ ដែលមានចំនួន ៣១៥ ៣៣២ហិកតា គឺកើនឡើងចំនួន៤ ៨៥២ហិកតា ស្មើនឹង១,៥% (ដ្យាក្រាមទី៥)។ ទិន្នផលមធ្យមមានចំនួន១ ២២៨គ.ក្រ/ហ.ត បើធៀបនឹងឆ្នាំ២០២២ ដែលមានចំនួន១ ២១២គ.ក្រ/ហ.ត គឺកើនឡើងចំនួន១៦ គ.ក្រ/ហ.ត ស្មើនឹង១,៣% ដោយសារផ្ទៃដីកៅស៊ូយកផលកន្លងមកដល់អាយុពេញឱ្យផល (ឧបសម្ព័ន្ធទី១៣ និងទី១៥)។




ដ្យាក្រាមទី៥៖ ផ្ទៃដីកៅស៊ូយកផល ថែទាំ និងសរុប ឆ្នាំ២០១៩-២០២៣

៣៤- ផលិតផលកៅស៊ូក្នុងឆ្នាំ២០២៣ សម្រេចបានចំនួន៣៩១ ៨០០តោន កើនឡើងចំនួន៩ ៨០០តោន ស្មើ ២,៥៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២។ ការនាំចេញកៅស៊ូសម្រេចបានចំនួន៣៦៨ ០៤៨តោន ស្មើនឹងទឹកប្រាក់ចំនួន៤៩០,៦លានដុល្លារសហរដ្ឋអាម៉េរិក ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២ ដែលការនាំចេញមានចំនួន៣៧២ ៩០០តោន ស្មើនឹងទឹកប្រាក់ចំនួន៥២៧,៧៧៤លានដុល្លារសហរដ្ឋអាម៉េរិក ឃើញថាបរិមាណនាំចេញថយចុះចំនួន៤ ៨៥២តោន ស្មើនឹង១,៣% និងថយចុះប្រមាណ៣៧,១៦៦លានដុល្លារសហរដ្ឋអាម៉េរិក ស្មើនឹង៧,០៤% (ដ្យាក្រាមទី៦)។ ក្នុងឆ្នាំ២០២៣នេះ ថ្លៃកៅស៊ូធម្មជាតិគិតជាមធ្យម១ ៣៣៣ដុល្លារសហរដ្ឋអាម៉េរិក/តោន គឺបានថយចុះ៨២ដុល្លារសហរដ្ឋអាម៉េរិក/តោន ស្មើនឹង៥,៧៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២ ដែលមានថ្លៃមធ្យម១ ៤១៥ដុល្លារសហរដ្ឋអាម៉េរិក/តោន (ឧបសម្ព័ន្ធទី១២ ទី១៣ និងទី១៤)។ កត្តាដែលមានឥទ្ធិពលលើថ្លៃកៅស៊ូធម្មជាតិ ដោយសារអតុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ ការផ្គត់ផ្គង់កៅស៊ូធម្មជាតិបានថយចុះ មកពីបណ្តាប្រទេសផលិតមួយចំនួនជួបវិបត្តិដូចជា៖ ទឹកជំនន់នៅបណ្តាខេត្តនៃភាគខាងត្បូងប្រទេសថៃ ជំងឺស្លឹកប្រភេទថ្មីបានឆ្លងរីករាលដាលជាសកលនៅប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ស្រីលង្កា និងឥណ្ឌា។ រួមផ្សំដោយកត្តាមិនមែនមូលដ្ឋានមួយចំនួនទៀតដូចជា៖ ថ្លៃប្រេងកើនឡើងយ៉ាងគំហុក ដោយសារវិបត្តិកង្វះធ្យូងថ្មដ៏ធ្ងន់ធ្ងរសម្រាប់ម៉ាស៊ីនផលិតថាមពលអគ្គីសនី ដែលប្តូរមកប្រើប្រាស់ប្រេងឥន្ធនៈនិងម៉ាស៊ូតជំនួសវិញ ភាពប្រសើរឡើងវិញនូវកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងប្រទេសអាម៉េរិកនិងចិន និងស្របពេលដែលតម្រូវការកៅស៊ូធម្មជាតិពិភពលោកនៅតែមានកំណើនខ្ពស់។

៣៥- ផលិតផលកៅស៊ូប្រើប្រាស់ក្នុងស្រុក ឆ្នាំ២០២៣ សម្រេចបានចំនួន៣០ ៤៥២តោន ស្មើនឹងទឹកប្រាក់ ៤៥,៦៧៨លានដុល្លារសហរដ្ឋអាម៉េរិក ថ្លៃកៅស៊ូធម្មជាតិគិតជាមធ្យម១ ៥០០ដុល្លារសហរដ្ឋអាម៉េរិក/តោន។




ដ្យាក្រាមទី៦៖ ផលិតផលនិងការនាំចេញកៅស៊ូធម្មជាតិ ឆ្នាំ២០១៩-២០២៣

៣៦- នៅក្នុងឆ្នាំ២០២៣ ការនាំចេញឈើកៅស៊ូពីការកាប់ដើមកៅស៊ូចាស់ៗចំនួន៩ ៤១១ម៉ែត្រគូប ទទួលបានទឹកប្រាក់១ ៥៩១ ៨៧២ដុល្លារអាម៉េរិក។

## ២.៣.២ រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ

៣៧- មកដល់ឆ្នាំ២០២៣នេះ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូមានចំនួនសរុប១៧៣កន្លែង ធៀបនឹងចំនួនរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូឆ្នាំ២០២២ មានចំនួន១៧២កន្លែង កើនឡើងចំនួន១កន្លែង ស្មើនឹង០,៥៨%។ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: Technically Specified Rubber) ចំនួន៥៣កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: Concentrated Latex) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air-Dried Sheet) មានចំនួន៩៩កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន២០កន្លែង (ដ្យាក្រាមទី៧និងឧបសម្ព័ន្ធទី១៥)។




ដ្យាក្រាមទី៧៖ រោងចក្រ សិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ ២០១៩-២០២៣

៣៨- ក្នុងឆ្នាំ២០២៣នេះ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូចំនួន១០៨កន្លែងបានផ្អាកដំណើរការ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: Technically Specified Rubber) ចំនួន១៩កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: Concentrated Latex) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air-Dried Sheet) មានចំនួន៧៧កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន១១កន្លែង។ ការផ្អាកដំណើរការនេះ ដោយសារខ្វះវត្ថុធាតុដើម ខ្វះទុនបម្រុង ថ្លៃដើមផលិតខ្ពស់ ផលិតផលមិនបំពេញតម្រូវការទីផ្សារ និងប្រព័ន្ធផលិតកម្មកែច្នៃមិនទាន់ល្អប្រសើរ។

៣៩- អត្រាគុណភាពកៅស៊ូល្អ (CSR L, CSR 5, CSR 10 និងRSS1) ឆ្នាំ២០១៩អនុវត្តបានចំនួន៧៨% ឆ្នាំ២០២០-២០២១ មានចំនួន៧៨,៥% ឆ្នាំ២០២២អនុវត្តបានចំនួន៧៨,៧០% និងឆ្នាំ២០២៣អនុវត្តបានចំនួន៧៩,៣០%(ដ្យាក្រាមទី៨)។




ដ្យាក្រាមទី៨៖ អត្រាគុណភាពកៅស៊ូល្អ (CSR L, CSR 5, CSR 10 និងRSS1) ឆ្នាំ២០១៩-២០២៣

## ២.៣.៣ កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ

៤០- ក្នុងឆ្នាំ២០២៣ អនុវិស័យកៅស៊ូបានប្រើប្រាស់កម្លាំងពលកម្មផ្នែកសំខាន់ៗសរុបចំនួនប្រមាណ១៤៤ ៦៦០ នាក់ ដែលក្នុងនោះមាន៖ កម្លាំងពលកម្មក្នុងផ្នែកយកផលមានចំនួនប្រមាណ១១៣ ៨៤៣នាក់ កម្លាំងពលកម្មក្នុងផ្នែកថែទាំមានចំនួនប្រមាណ១៧ ៣៩៨នាក់ កម្លាំងពលកម្មក្នុងផ្នែកកែច្នៃមានចំនួនប្រមាន៦ ៥៣០នាក់ និងកម្លាំងពលកម្មក្នុងផ្នែកការងាររដ្ឋបាលមានចំនួន៦ ៨៨៩នាក់ (តារាងទី៤)។

តារាងទី៤៖ ស្ថានភាពនៃការប្រើប្រាស់កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ (នាក់)

| ប្រភេទកម្លាំងពលកម្ម | ឆ្នាំ | | | | |
|---|---|---|---|---|---|
| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| យកផល | ៨៩ ០៥៨ | ១០៤ ០០០ | ១១០ ២៩១ | ១១២ ១១៨ | ១១៣ ៨៤៣ |
| ថែទាំ | ៣១ ០៣៩ | ២២ ៣៣២ | ១៨ ៧៧០ | ១៧ ៨៤៩ | ១៧ ៣៩៨ |
| កែច្នៃ | ៤ ៧៩៤ | ៥ ៨២២ | ៦ ១៣៣ | ៦ ៣៦៧ | ៦ ៥៣០ |
| រដ្ឋបាល | ៦ ២៤៥ | ៦ ៦០៨ | ៦ ៧៦០ | ៦ ៨៩៨ | ៦ ៨៨៩ |
| សរុប | ១៣១ ១៣៦ | ១៣៨ ៧៦២ | ១៤១ ៩៥៤ | ១៤៣ ២៣២ | ១៤៤ ៦៦០ |

## ២.៤ ការងារបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសិក្ខាសាលា

### ៤១- ការងារសិក្ខាសាលា ផ្សព្វផ្សាយ និងបណ្តុះបណ្តាល

- បានរៀបចំសិក្ខាសាលាស្តីពី "ការវិវត្តកៅស៊ូធម្មជាតិ" ចំនួន២លើក នៅខេត្តកំពង់ចាម ដោយមានមន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ មន្ត្រីការិយាល័យកៅស៊ូតាមខេត្ត និងបុគ្គលិកតាមបណ្តាក្រុមហ៊ុនអវិនិយោគនិងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចូលរួមសរុបចំនួន៥៥នាក់
- បានរៀបចំសិក្ខាសាលាស្តីពី "ការរៀបចំគម្រោងសកម្មភាពថវិកាកម្មវិធី ការតាមដាននិងការវាយតម្លៃលើការចំណាយសកម្មភាពថវិកាកម្មវិធីដោយប្រើឧបករណ៍ Excel ជឿនលឿន" ចំនួន១លើក នៅអគ្គនាយកដ្ឋានកៅស៊ូ ដោយមានមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ ចូលរួមសរុបចំនួន៤០នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាល "សមត្ថភាពជំនាញដល់មន្ត្រីរាជការ" ចំនួន១លើក នៅអគ្គនាយកដ្ឋានកៅស៊ូ ដោយមានមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ ចូលរួមសរុបចំនួន៣០នាក់
- បានបើកវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអនុវិស័យកៅស៊ូ ចំនួន៣លើក នៅខេត្តប៉ៃលិន ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុបចំនួន១២០នាក់
- បានបើកវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយទីផ្សារកៅស៊ូដល់កសិករកៅស៊ូគ្រួសារ ចំនួន៣លើក នៅខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដោយមានកសិករចូលរួមសរុបចំនួន៨៧នាក់
- បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកែច្នៃ ដល់ម្ចាស់រោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូនិងឈើកៅស៊ូ ចំនួន១លើក នៅខេត្តកំពង់ចាម ដោយមានអ្នកចូលរួមសរុបចំនួន៣១នាក់
- បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកែច្នៃដល់សហគមន៍កៅស៊ូគ្រួសារ ចំនួន៤លើក នៅខេត្តត្បូងឃ្មុំនិងខេត្តកំពង់ធំ ដោយមានអ្នកចូលរួមសរុបចំនួន១៤៥នាក់
- បានបើកវគ្គសិក្ខាសាលាស្តីពី "ការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោល" ចំនួន១លើក នៅខេត្តសៀមរាប ដោយមានមន្ត្រីមកពីការិយាល័យកៅស៊ូចំនួន២១ខេត្តបានចូលរួម រួមមាន៖ ខេត្តស្វាយរៀង ព្រៃវែង ក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន ពោធិ៍សាត់ កំពង់ឆ្នាំង ព្រះសីហនុ តាកែវ កែប កំពត សៀមរាប និងខេត្តព្រះវិហារ សរុបចំនួន៣៥នាក់
- បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ ចំនួន២លើក នៅខេត្តបាត់ដំបងនិងខេត្តប៉ៃលិន ដោយមានកសិករចូលរួមសរុបចំនួន១០០នាក់
- បានគាំទ្ររៀបចំការចិញ្ចឹមឃ្មុំក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារចំនួន២សហគមន៍ នៅខេត្តមណ្ឌលគិរីនិងខេត្តរតនគិរី
- បានពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារបានចំនួន៥សហគមន៍ នៅខេត្តរតនគិរី ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ និងខេត្តស្ទឹងត្រែង
- បានចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារចំនួន១ នៅខេត្តមណ្ឌលគិរី
- បានតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ ចំនួន៧លើក នៅខេត្តរតនគិរី មណ្ឌលគីរី ក្រចេះ ត្បូងឃ្មុំ កំពង់ធំ និងខេត្តសៀមរាប
- បានចុះតាមដានការអនុវត្តថវិកាកម្មវិធីលើសកម្មភាពចំនួន៧លើក៖ (ក) នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ ចំនួន៤លើក លើសកម្មភាព (១) ការបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ (២) ពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ (៣) ចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ និង(៤)គាំទ្ររៀបចំការចិញ្ចឹម

ឃុំក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ (ខ) នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូចំនួន១លើក លើសកម្មភាព "បណ្តុះបណ្តាលបច្ចេកទេសកែច្នៃដល់សហគមន៍កៅស៊ូ" (គ) នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិចំនួន១ លើសកម្មភាព "ផ្សព្វផ្សាយនិងបណ្តុះបណ្តាលទីផ្សារកៅស៊ូដល់កសិករកៅស៊ូគ្រួសារ" និង (ឃ) នាយកដ្ឋានរដ្ឋបាលនិងនីតិកម្មចំនួន១លើក លើសកម្មភាព "ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអនុវិស័យកៅស៊ូ"

- បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី "ការអនុវត្តកសិកម្មល្អសម្រាប់ដំណាំកៅស៊ូ" នៅស្ថានីយពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដោយមានអ្នកចូលរួមសរុបចំនួន៥៤នាក់
- បានចូលរួមបណ្តុះបណ្តាលនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- បានបោះពុម្ពព្រឹត្តិបត្រកៅស៊ូធម្មជាតិ ចំនួន២ ១៦០ច្បាប់
- ថែទាំប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកៅស៊ូតាមអេឡិចត្រូនិច។

**៤២- ការចូលរួមវគ្គសិក្ខាសាលានិងបណ្តុះបណ្តាលក្នុងប្រទេស**

- បានចូលរួមសិក្ខាសាលាស្តីពី "ការត្រៀមបម្រុងសម្រាប់ការរៀបចំរបាយការណ៍តម្លាភាពពីរឆ្នាំម្តង (BTR)" នៅសណ្ឋាគារកាំប៊ូឌីយ៉ាណា
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រងភូមិសាស្ត្របច្ចេកវិទ្យាឆ្លាតវៃលើវិស័យកសិកម្ម (Intelligent Technology for Geospatial Management on Agriculture for Cambodia)" នៅសណ្ឋាគារសាន់វ៉េនមូនភ្នំពេញ
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការប្រើប្រាស់ទិន្នន័យកសិកម្ម" នៅខេត្តកំពត
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការធ្វើសារពើព័ន្ធឧស្ម័នផ្ទះកញ្ចក់" នៅខេត្តសៀមរាប
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី "ការបង្កើតគំរូ GIS Model សម្រាប់គាំទ្រដល់ការកំណត់និងការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ" នៅខេត្តសៀមរាប
- បានចូលរួមសិក្ខាសាលាស្តីពី "ការស្វែងយល់អំពីប្រភេទមុខទំនិញ និងមធ្យោបាយយុត្តាធិការ ដើម្បីកាត់បន្ថយការកាប់បំផ្លាញព្រៃឈើសម្រាប់តំបន់ទន្លេមេគង្គក្រោម (Exploring Commodity and Jurisdictional Approaches to Decoupling from Deforestation for the Lower Mekong Region)" នៅខេត្តសៀមរាប
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "English for Effective Negotiation" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី (CSCC)
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "សារៈសំខាន់នៃបច្ចេកវិទ្យាព័ត៌មាន និងសុវត្ថិភាព នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម" នៅខេត្តសៀមរាប
- បានចូលរួមវគ្គបណ្តុះបណ្តាលតម្រង់ទិសដំបូងសម្រាប់សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅសាលាភូមិន្ទរដ្ឋបាល
- បានចូលរួមវគ្គបណ្តុះបណ្តាលការពង្រឹងសមត្ថភាពលើការងាររដ្ឋបាលនិងបុគ្គលិក នៅខេត្តកែប
- បានចូលរួមវគ្គចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីជំរឿនកសិកម្មនៅរាជធានីខេត្តទាំង២៥ នៅក្រសួងផែនការ
- បានចូលរួមវគ្គចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី "វិធីសាស្ត្រប្រមូលទិន្នន័យអង្កេតកសិកម្មឆ្នាំ២០២៣" នៅក្រសួងផែនការ
- បានចូលរួមវគ្គបណ្តុះបណ្តាលការវាយតម្លៃផលប៉ះពាល់និងការប្រើប្រាស់ទិន្នន័យដើម្បីតាមដាននិងវាយតម្លៃ នៅភោជនីយដ្ឋានទន្លេបាសាក់២

- បានចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ តាមប្រព័ន្ធអនឡាញនិងផ្ទាល់នៅសាលាភូមិន្ទរដ្ឋបាល។

៤៣- **ការចូលរួមវគ្គសិក្ខាសាលានិងបណ្តុះបណ្តាលក្រៅប្រទេស**

- បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិតវិស្វកម្មកសិកម្ម "Agricultural Engineering" នៅប្រទេសថៃ
- បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ "កសិកម្មនិងអភិវឌ្ឍន៍ជនបទ" នៅប្រទេសជប៉ុន
- បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិត "សេដ្ឋកិច្ចកសិកម្ម" នៅប្រទេសកូរ៉េ
- បានចូលរួមវគ្គបណ្តុះបណ្តាល Tropical Fruit Production and Processing Techniques in developing countries នៅប្រទេសចិន
- បានចូលរួមវគ្គបណ្តុះបណ្តាល PEFC Chain of Custody Initial Training នៅប្រទេសវៀតណាម។

## ២.៥ ការងារពិសោធន៍និងស្រាវជ្រាវ

៤៤- ក្នុងឆ្នាំ២០២៣នេះ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (**វ.ស.ក.ក.**) បានអនុវត្តនិងបន្តការងារស្រាវជ្រាវ តាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ សរុបមាន៦២ចម្ការពិសោធន៍។ ទន្ទឹមគ្នានឹងការស្រាវជ្រាវ **វ.ស.ក.ក.** បានរួមចំណែកយ៉ាងធំធេងនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដោយការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ព្រមជាមួយគ្នានោះក៏បានបណ្តុះបណ្តាលនូវធនធានមនុស្សតាមរយៈការបង្ហាត់បង្រៀននិស្សិតនៅតាមគ្រឹះស្ថានសិក្សា និងការសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សាចម្ការពិសោធន៍ និងការដឹកនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតមកពីគ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួន ដើម្បីបន្តវេនក្នុងការអភិវឌ្ឍដំណាំកៅស៊ូនាអនាគត។

៤៥- ការងារដែលបាននិងកំពុងអនុវត្តលើការស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រ៖

- **ការងារដាំដុះនិងការពារ**៖ បានរៀបចំចម្ការពិសោធន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រដាំដុះ ការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងជីជាតិដី បង្កើនប្រសិទ្ធភាពនៃចម្ការនិងការប្រើប្រាស់ដី បង្កើតនូវចំណូលបន្ថែម តាមរយៈការធ្វើពិពិធកម្មកៅស៊ូជាមួយនិងប្រភេទដំណាំនិងរុក្ខជាតិផ្សេងទៀត។ ក្នុងឆ្នាំ២០២៣ បាន (១)តាមដានស្រង់បញ្ចូលនិងវិភាគទិន្នន័យចម្ការពិសោធន៍រួមមាន (ក)អភិវឌ្ឍន៍រុក្ខសម្ភារដាំដុះ (ខ)ការប្រើប្រាស់ជីលើកៅស៊ូមិនទាន់ផ្តល់ផល និងកៅស៊ូផ្តល់ផល (គ)ការធ្វើពិពិធកម្មដំណាំរួមផ្សំនិងរុក្ខជាតិព្រៃនៅចន្លោះកៅស៊ូ (ឃ)ដំណាំគម្របដី ផលិតផលជីវម៉ាស់ និងវិធានការគ្រប់គ្រងដំណាំគម្របដី (ង)សិក្សាទំនាក់ទំនងរវាងការលូតលាស់និងទិន្នផល លើអាកាសធាតុនិងចង្វាក់ចៀរជ័រd3និងd4 (ច)ដង់ស៊ីតេដាំដុះដើមកៅស៊ូ (ឆ)ឥទ្ធិពលនៃការស្រោចស្រព លើការលូតលាស់និងទិន្នផលកៅស៊ូ (២)អនុវត្តការងារដាំដុះកូនកៅស៊ូលើផ្ទៃដី១២,៥ ហិកតា (ក្លូនPB280, សេណូទីប G7 និងRayan 7-33-97) និង(៣) រៀបចំថ្នាលបណ្តុះកៅស៊ូកៅស៊ូលើផ្ទៃដី ០,៣៥ហិកតា។
- **ការងារស្រាវជ្រាវអំពីការបង្កាត់ពូជ**៖ ការអភិវឌ្ឍពូជកៅស៊ូ ការងារដែលបានអនុវត្តនៅក្នុងផ្នែកបង្កាត់ពូជសំដៅធ្វើសុរុំឌ្ធិកម្មក្លូនកៅស៊ូ តាមរយៈការនាំចូល ការប្តូរក្លូនជាមួយនឹងបណ្តាប្រទេសជាសមាជិក IRRDB ការបង្កាត់និងធ្វើជម្រើសពូជ ការពង្រឹងគុណភាពរុក្ខសម្ភារជាពិសេសការគ្រប់គ្រងច្បារពូជ ការអភិវឌ្ឍក្លូនកៅស៊ូកម្ពុជា និងការផ្តល់ជាអនុសាសន៍ក្លូនកៅស៊ូសម្រាប់ការដាំដុះតាមដំណាក់កាល ឆ្លើយតបទៅនឹងលក្ខខណ្ឌក្សេត្របរិស្ថានតាមតំបន់ ក្នុងគោលបំណងបង្កើននូវផលិតភាព បង្កើននូវចំណូលដល់អ្នកដាំដុះ

កៅស៊ូ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងឆ្នាំ២០២៣ បាន (១)តាមដានស្រង់និងបញ្ចូលទិន្នន័យចំនួន២៣ចម្ការពិសោធន៍ នៅស្ថានីយ៍អនុវត្តនៃ វ.ស.ក.ក ក្រុមហ៊ុនក្រែក ខេមបូឌា ក្រុមហ៊ុនទ្រីភាព បឹងទន្លេរម្រេច និងក្រុមហ៊ុន SOCFIN-KCD (២)ស្រង់ទិន្នន័យជំងឺប្រផេះស (Oidium) ចំនួន១១ចម្ការពិសោធន៍ នៅស្ថានីយ៍ពិសោធន៍ក្លូនរបស់ វ.ស.ក.ក (៣)បានបង្កើតចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំនៅស្ថានីយ៍ពិសោធន៍ វ.ស.ក.ក (IR.AA.13) និងក្រុមហ៊ុនចម្ការកៅស៊ូមេមត់ (MM.AA.01) (៤)ដាំក្លូនកៅស៊ូក្លូន G7, Rayan 7-33-97 ក្លូនកៅស៊ូទទួលបានពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន វិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន(CATAS-RRI) (៥)ត្រួតពិនិត្យច្បារពូជកៅស៊ូនៅចម្ការកៅស៊ូមេមត់ លើផ្ទៃដី៥,១៥ហិកតា ដែលមានក្លូនចំនួន២៧ក្លូន (៦)ផ្តល់ក្លូនកៅស៊ូចំនួន១២ ដល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូវៀតណាម (RRIV) និង១២ក្លូនដល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (CATAS-RRI) (៧)ទទួលមែកពូជកៅស៊ូក្លូន(Rayan 879) ពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (CATAS-RRI) ហើយបំបៅបានចំនួន៣៣ដើម (៨)វាយតម្លៃនិងកំណត់យកក្លូនកៅស៊ូ G12 និងG19 សម្រាប់បញ្ចេញប្រើប្រាស់នៅកម្ពុជា និង(៩)រៀបចំនិងបោះពុម្ពផ្សព្វផ្សាយនូវអត្ថបទបច្ចេកទេសស្តីពីអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០២៣-២០២៥។

- **សកម្មភាពស្រាវជ្រាវលើសរីរសាស្ត្រនិងការយកផលទឹកជ័រ៖** ការសិក្សាអំពីសរីរសាស្ត្រ និងការប្រមូលផលទឹកជ័រ គឺសំដៅអនុវត្តនូវវិធីសាស្ត្រប្រមូលផលទឹកជ័រប្រកបដោយប្រសិទ្ធភាព និងអស់ពីសក្តានុពលនៃក្លូនកៅស៊ូ ព្រមជាមួយនិងការរក្សាបាននូវចីរភាពនៃការប្រមូលផលផងដែរ។ ក្នុងឆ្នាំ២០២៣ បាន (១)តាមដានស្រង់ បញ្ចូលទិន្នន័យចម្ការពិសោធន៍នៅក្នុងស្ថានីយ៍ចំនួន១៣ និងក្រៅស្ថានីយចំនួន១ចម្ការពិសោធន៍រួមមាន៖ (ក)សក្តានុពលទិន្នផលប្រព័ន្ធចង្វាក់ចៀរd3 និងd4 (ខ)ប្រព័ន្ធចង្វាក់ចៀររង្វើល d3, d4, d5 និងd6 (គ)ការបើកមុខចៀរលើទំហំដើមខុសគ្នា (២)បង្កើតចម្ការពិសោធន៍អំពីប្រព័ន្ធចង្វាក់ចៀររង្វើល d3, d4, d5 & d6 នៅក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខេត្តក្រចេះ និង d4, d6, d8 និងd10 នៅចម្ការកៅស៊ូ Coviphama ខេត្តមណ្ឌលគិរី និង(៣)យកសំណាកនិងវិភាគសរីរៈទឹកជ័រពីចម្ការកៅស៊ូតាមបណ្តាក្រុមហ៊ុននានានិងស្ថានីយ៍ពិសោធន៍(ផុប) បានចំនួន១ ៤២៨សំណាក។
- **សកម្មភាពស្ថានីយអនុវត្តន៍៖** ត្រួតពិនិត្យការចាត់ចែងកម្លាំងប្រមូលផលជ័រ រៀបចំបែងចែកវានចៀរជ័រសម្រាប់កម្មករ ថែទាំកៅស៊ូកំពុងផ្តល់ផល អនុវត្តការកែច្នៃកៅស៊ូសន្លឹក និងជួសជុលថែទាំឧបករណ៍កែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ ត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូនជ័រ គ្រឿងចក្របម្រើឱ្យការងារកសិកម្ម ម៉ាស៊ីនទឹកស្រោចស្រពកូនកៅស៊ូ ការថែទាំបណ្តាញទឹក បណ្តាញភ្លើង អគារស្នាក់នៅរបស់មន្ត្រីរាជការ កម្មករនិយោជិត និងអគារ កន្លែងធ្វើការ ផ្គត់ផ្គង់ប្រេងឥន្ធនៈដល់ផ្នែកគ្រឿងចក្ររថយន្តដឹកជញ្ជូន និងអង្ករ ទឹក ភ្លើងជូនមន្ត្រីរាជការ បុគ្គលិក កម្មករ ទទួលភ្ញៀវមកទស្សនកិច្ចសិក្សាស្វែងយល់ការងារពិសោធស្រាវជ្រាវ ការពារសម្អាតកន្លែងស្នាក់នៅរបស់មន្ត្រីរាជការ បុគ្គលិកកម្មករនៅក្នុងស្ថានីយ។
- **ការងារផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ៖** អនុវត្តការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទតាមប្រព័ន្ធ គ្រប់គ្រងគុណភាព ISO/IEC 17025: 2017 បានធ្វើតេស្តកៅស៊ូសន្លឹក (RSS) របស់ វ.ស.ក.ក. សរុបចំនួន៨០សំណាក ដើម្បីពិនិត្យគុណភាព នៃការកែច្នៃតាមស្តង់ដា CSR បានធ្វើតេស្តកៅស៊ូដុំCSR, TSR ចំនួន៧៦សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដារកៅស៊ូCSR សម្រាប់រោងចក្រ និងមន្ទីរពិសោធន៍ដែលបានស្នើសុំបន្តសុពលភាពបញ្ជិកា និងចុះបញ្ជិកាថ្មី មុននឹងផ្តល់វិញ្ញាបនត្រជូនដល់រោងចក្រ និងមន្ទីរពិសោធន៍ បានចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ អន្តរជាតិក្នុងក្របខ័ណ្ឌសមាគមកៅស៊ូអន្តរ

ជាតិ (IRA) ចំនួន២លើក (ទី១២៨និងទី១២៩) បានធ្វើតេស្តប្រៀបធៀប ក្នុងស្រុកជាមួយមន្ទីរសោធន៍មូលដ្ឋាន លើកទី៦៤និង៦៥ ដែលមានចំនួន១២មន្ទីរពិសោធន៍មូលដ្ឋាន និងបានបានចុះបញ្ជិកាពោងចក្រកែច្នៃកៅស៊ូនិងសិទ្ធប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា(CSR) ចំនួន១៣ និងមន្ទីរពិសោធន៍ចំនួន៦។

## ២.៦ ការងារសហប្រតិបត្តិការអន្តរជាតិ

### ២.៦.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ

(Association of Natural Rubber Producing Countries: ANRPC)

៤៦- កម្ពុជាបានចូលជាសមាជិកពេញសិទ្ធនៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩។ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ គឺជាអង្គការអន្តររដ្ឋាភិបាលដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០។ សមាជិកភាពរបស់សមាគមត្រូវបានបើកទូលាយចំពោះរដ្ឋាភិបាលនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ រហូតមកដល់ឆ្នាំ២០២៣ សមាគមនេះមានប្រទេសជាសមាជិកចំនួន ១៣ ប្រទេសរួមមាន៖ បង់ក្លាដេស កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ប៉ាពូញូហ្គីណេ ភីលីពីន សឹង្ហបុរី ស្រីលង្កា ថៃ និងវៀតណាម។ ***ទស្សនៈវិស័យ*** របស់សមាគម គឺធ្វើឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិ មានចីរភាពប្រកបដោយលក្ខណៈសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ***បេសកកម្ម*** គឺកែលម្អជាបន្តបន្ទាប់នូវផលិតភាពនៃកៅស៊ូគ្រួសារ កាត់បន្ថយចំណាយ បង្កើនតម្លៃបន្ថែមផ្នែកលំហូរខាងក្រោម រកប្រភពប្រាក់ចំណូលបន្ថែម ប្រើប្រាស់លទ្ធភាព និងបទពិសោធន៍សម្រាប់ជួយបរិស្ថាននិងបង្កើនសុខុមាលភាពរបស់កសិករកៅស៊ូគ្រួសារ។

តារាងទី៥៖ កម្មវិធីសន្និសីទ កិច្ចប្រជុំ និងសន្និបាតរបស់សមាគម ANRPC ក្នុងឆ្នាំ២០២៣

| ល.រ | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ |
|---|---|---|
| ១ | សន្និសីទកៅស៊ូប្រចាំឆ្នាំលើកទី១៣ | ០៩ តុលា ឆ្នាំ២០២៣ |
| ២ | កិច្ចប្រជុំលើកទី៦ រវាងផ្នែករដ្ឋនៃសមាគមនិងផ្នែកឯកជន | ១០ តុលា ឆ្នាំ២០២៣ |
| ៣ | កិច្ចប្រជុំលើកទី១៦ របស់គណៈកម្មាធិការព័ត៌មាននិងស្ថិតិ | ១១ តុលា ឆ្នាំ២០២៣ |
| ៤ | កិច្ចប្រជុំលើកទី៤៥ របស់គណៈកម្មាធិការប្រតិបត្តិ | ១៣ តុលា ឆ្នាំ២០២៣ |

### ២.៦.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ

( International Rubber Research And Development Board: IRRDB)

៤៧- ឆ្នាំ២០២៣នេះ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានចូលរួម (១) សន្និសីទកៅស៊ូអន្តរជាតិរបស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិឆ្នាំ២០២៣ (២) កិច្ចប្រជុំគណៈកម្មការគ្រប់គ្រង និង(៣) កិច្ចប្រជុំគណៈកម្មការហិរញ្ញវត្ថុ។

### ២.៦.៣ កិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន

៤៨- ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានអនុស្សរណៈយោគយល់គ្នាជាមួយភាគីចិន ដែលបានចុះហត្ថលេខានាថ្ងៃទី១៥

ខែតុលា ឆ្នាំ២០១៥ កន្លងមកនិងនៅមានសុពលភាពរហូតដល់បច្ចុប្បន្ន។ នៅក្នុងឆ្នាំ២០២៤ បាន៖ (១)បញ្ជូនមន្ត្រីជំនាញចំនួន០៤រូប ទៅចូលរួមសិក្ខាសាលាស្តីពី “Natural Rubber Production and Management” ដែលប្រព្រឹត្តនៅទីក្រុងហាយគុត ខេត្តហាយណាន ប្រទេសចិន និង(២) វិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (CATAS-RRI) បានផ្តល់មែកពូជកៅស៊ូក្លូន Reyan 879 ដល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

### ២.៦.៤ មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍ

(Centre De Coopération Internationale En Recherche Agronomique Pour Le Dévelopement :CIRAD)

៤៩- បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាទូទៅ (GMOU) កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ក្នុងគោលបំណងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរយៈពេលវែង រវាងភាគីទាំងពីរក្នុងការស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មនៅកម្ពុជា ដោយផ្តោតលើ (១)សេដ្ឋកិច្ចសង្គម (២)ការអនុវត្តកសិកម្មល្អ (៣)បច្ចេកវិទ្យាគុណភាពកៅស៊ូ (៤)ការប្រើប្រាស់និងវាយតម្លៃគុណភាពដីនិងដី (៥)ការធ្វើផែនទីនិងកំណត់តំបន់ដាំដុះ (៦)ជីវបច្ចេកវិទ្យា (Bio-Technology) (៧)បរិស្ថាននិងការប្រែប្រួលអាកាសធាតុ (៨)ការកសាងធនធានមនុស្ស (៩)ទស្សនៈកិច្ចសិក្សា និង(១០) ការផ្លាស់ប្តូរកម្មវិធីសិក្សាសម្រាប់មន្ត្រីជំនាញ នៃអង្គភាពទាំងពីរ។

៥០- នៅក្នុងឆ្នាំ២០២៣ (១)បានចូលរួមកិច្ចប្រជុំ Kick-off Meeting, Steering Committee Meeting and Board Meeting នៃគម្រោង FORSEA នៅទីក្រុងបាងកក ប្រទេសថៃ (២)បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Practice of anticipant in FORSEA project (៣)បានចូលរួមប្រជុំជ្រើសរើសសំណាកនិងកែសម្រួលបញ្ជីសំណួរសម្រាប់សម្ភារអំពីកម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ (៤)ចុះសាកល្បងបញ្ជីសំណួរជាមួយកសិករកៅស៊ូគ្រួសារ សហគមន៍កសិកម្មកៅស៊ូគ្រួសារ ក្រុមហ៊ុនកសិឧស្សាហកម្មនិងវិស័យសាធារណៈ (៥)បានបញ្ជូនមន្ត្រី១រូប ទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និង(៦)ពិសោធន៍ស្រាវជ្រាវលើគុណភាពជ័រកៅស៊ូដែលអនុវត្តប្រព័ន្ធចៀរខុសគ្នា d4 d5 និងd6។

### ២.៦.៥ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍

(Agence Française De Développement: AFD)

៥១- ឆ្នាំ២០២៣ អគ្គនាយកដ្ឋានកៅស៊ូបានចូលរួមប្រជុំពិភាក្សាការងារជាមួយលោកស្រី Sandrine BOUCHER នាយិកាទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍប្រចាំនៅកម្ពុជា ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង FORSEA។

### ២.៦.៦ អង្គការមូលនិធិសកលសម្រាប់ធម្មជាតិ (World Wide Fund for Nature: WWF) ប្រចាំព្រះរាជាណាចក្រកម្ពុជា

៥២- នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហការលើការគាំទ្រនិងការអភិវឌ្ឍអនុវិស័យកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព នៅតំបន់ខ្ពង់រាបភាគខាងកើត (ខេត្តមណ្ឌលគិរី)។ អនុស្សរណៈនៃការយោគយល់គ្នានេះមានគោលបំណង (១)ចូលរួមកសាងនិងបញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍កៅស៊ូធម្មជាតិប្រកបដោយចីរភាពដល់អ្នកពាក់ព័ន្ធ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូ (២)ចូលរួមរៀបចំនិងពង្រឹងដំណើការយន្តការភាពជាដៃគូពហុភាគីនៅក្នុងខេត្តមណ្ឌលគិរី (៣)ចូលរួមពង្រឹងដំណើរការសហគមន៍កសិកម្មកៅស៊ូគ្រួសារ (៤)ចូលរួមបង្កើតនិងពង្រឹងសេវាកម្មផ្សព្វផ្សាយ

លើបច្ចេកទេសដំណាំកៅស៊ូប្រកបដោយចីរភាពឱ្យបានកាន់តែទូលំទូលាយនិងមានប្រសិទ្ធភាព (៥)ចូលរួមរៀបចំចម្ការបង្ហាញបច្ចេកទេសដំណាំកៅស៊ូនិងពិពិធកម្មកសិកម្ម ដើម្បីធ្វើជាកន្លែងអនុវត្តនិងផ្សព្វផ្សាយបច្ចេកទេសដល់អ្នកដាំកៅស៊ូ (៦)រៀបចំបង្កើតកិច្ចប្រជុំដើម្បីចែករំលែកមេរៀនបទពិសោធន៍និងលទ្ធផលនៃកិច្ចសហប្រតិបត្តិការ (៧)ចូលរួមសិក្សាលក្ខណៈសម្បត្តិ (Profile) និងការកំណត់ទីតាំងចម្ការកៅស៊ូគ្រួសារបង្កើត Mapping និង (៨)ចូលរួមពិភាក្សាជាមួយគ្នាលើគំនិតផ្តួចផ្តើម និងការរៀបចំគម្រោងថ្មីៗ។ នៅក្នុងឆ្នាំ ២០២៣ អគ្គនាយកដ្ឋានកៅស៊ូបានសហការអនុវត្តដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- បានចុះពង្រឹងនិងចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ ខេត្តមណ្ឌលគិរី
- បានរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័ររបស់កៅស៊ូគ្រួសារ នៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី
- បានបញ្ចប់ការផលិតនិងផ្សព្វផ្សាយវីដេអូរបច្ចេកទេសខ្លីៗស្តីពី "ការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ"
- បានបណ្តុះបណ្តាលបច្ចេកទេសការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ ដល់ជនបង្គោលនិងកសិករកៅស៊ូគ្រួសារ
- បានចូលរួមប្រជុំរៀបចំវេទិកាភាពជាដៃគូពហុភាគី
- បានប្រជុំពិភាក្សាជ្រើសរើសទីប្រឹក្សាឯករាជ្យ ដើម្បីរៀបចំគោលការណ៍និរន្តរភាពកៅស៊ូធម្មជាតិនៅកម្ពុជា
- បានរៀបចំសិក្ខាសាលពិគ្រោះយោបល់លើការរៀបចំគោលការណ៍និរន្តរភាពកៅស៊ូធម្មជាតិនៅកម្ពុជា
- បានរៀបបញ្ចប់របាយការណ៍គោលការណ៍និរន្តរភាពកៅស៊ូធម្មជាតិនៅកម្ពុជា។

## ២.៦.៧ អង្គការ OXFAM កម្ពុជា

៥៣- បានសហការជ្រើសរើសទីប្រឹក្សាឯករាជ្យ ដើម្បីសិក្សារៀបចំគោលការណ៍និរន្តរភាពកៅស៊ូធម្មជាតិនិងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលនៃការរៀបចំគោលការណ៍និរន្តរភាពកៅស៊ូធម្មជាតិនៅកម្ពុជា និងបានរៀបចំកម្មវិធីវេទិកាពិភាក្សារវាងអ្នកផ្គត់ផ្គង់និងអ្នកប្រើប្រាស់កៅស៊ូធម្មជាតិនៅខេត្តស្វាយរៀង ដោយមានការគាំទ្រផ្នែកហិរញ្ញប្បទានពីអង្គការ OXFAM អង្គការ WWF និងអង្គការ NGO FORUM ផងដែរ។

## ២.៦.៨ អង្គការ NGO FORUM

៥៤- បានសហការអនុវត្តការងារដូចខាងក្រោម៖

- ពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្មកៅស៊ូគ្រួសារខេត្តស្ទឹងត្រែងនិងរតនគិរី
- បណ្តុះបណ្តាលបច្ចេកទេសការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ ដល់សមាជិកសហគមន៍កសិកម្មកៅស៊ូគ្រួសារអូរយ៉ាដាវវល្លិ៍សាន
- រៀបចំឱ្យសហគមន៍កសិកម្មកៅស៊ូគ្រួសារអូរយ៉ាដាវវល្លិ៍សាន ទៅទស្សនកិច្ចនៅសហគមន៍កសិកម្មសំបូរមានជ័យនិងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- សហការជ្រើសរើសទីប្រឹក្សាឯករាជ្យដើម្បីសិក្សារៀបចំគោលការណ៍និរន្តរភាពកៅស៊ូធម្មជាតិ និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលនៃការរៀបចំគោលការណ៍និរន្តរភាពកៅស៊ូធម្មជាតិនៅកម្ពុជា។

### ២.៦.៩ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា (FAO)

៩៥- បានគាំទ្រផ្នែកថវិកាដល់មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានកៅស៊ូ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "PEFC Chain of Custody Initial Training" នៅប្រទេសវៀតណាម និងទស្សនកិច្ចសិក្សាស្វែងយល់អំពី "ប្រព័ន្ធគ្រប់គ្រងវិញ្ញាបនបត្រព្រៃឈើ (PEFC) របស់ក្រុមប្រឹក្សាវិញ្ញាបនបត្រព្រៃឈើប្រទេសថៃ" នៅទីក្រុងបាងកក ប្រទេសថៃ។

### ២.៦.១០ សម្ព័ន្ធឧស្សាហកម្មកៅស៊ូវៀតណាម VRG

៩៦- បានបន្តទំនាក់ទំនងជាមួយសម្ព័ន្ធឧស្សាហកម្មកៅស៊ូវៀតណាម ដើម្បីពិនិត្យនិងពន្លឿនលើការងារអនុស្សារណៈនៃការយោគយល់គ្នា(MoU)។

### ២.៦.១១ គម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ និងវៀតណាម (Cambodia Lao Vietnam Development Triangle Area: CLV DTA)

៩៧- ចាប់ពីឆ្នាំ២០១៤មក អគ្គនាយកដ្ឋានកៅស៊ូបានចូលរួមរៀបចំគម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ និងវៀតណាម។ យោងតាមលទ្ធផលនៃកិច្ចប្រជុំកំពូលកម្ពុជា ឡាវ វៀតណាម ស្តីពីការអភិវឌ្ឍតំបន់ត្រីកោណ (CLV DTA) លើកទី១១ តាមរយៈប្រព័ន្ធវីដេអូ ដែលបានរៀបចំនិងប្រព្រឹត្តិទៅ កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ នៅសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំពោះវិស័យឧស្សាហកម្មកៅស៊ូ គឺបានអនុម័តលើឯកសារ "*ផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្មកៅស៊ូ ប្រកបដោយចីរភាពក្នុងតំបន់អភិវឌ្ឍន៍នៃប្រទេសទាំង៣ កម្ពុជា ឡាវ វៀតណាម (CLV DTA)*"។ បន្ទាប់ពីកិច្ចប្រជុំកំពូល CLV DTA លើកទី១១ អគ្គនាយកដ្ឋានកៅស៊ូ៖ (១) បានធ្វើបច្ចុប្បន្នភាពលើរបាយការណ៍ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម ដោយបានកែសម្រួលលើទិន្នន័យ ផ្ទៃដីកៅស៊ូ ទិន្នផល ផលិតផលកៅស៊ូ និងរោងចក្រ និង (២) បានរៀបចំរបាយការណ៍វឌ្ឍនភាព លើរបាយការណ៍ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូប្រកបដោយនិរន្តរភាព ក្នុងតំបន់ត្រីកោណ អភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV DTA) រួចរាល់និងបានផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចាត់និតិវិធីបន្តទៅភាគីវៀតណាម។ រហូតមកដល់២០២៣នេះ អគ្គនាយកដ្ឋានកៅស៊ូ មិនទាន់ទទួលបានការឆ្លើយតបពីភាគីវៀតណាមអំពីវឌ្ឍន៍ភាពរៀបចំផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូកម្ពុជា-ឡាវ-វៀតណាមនៅឡើយទេ។ ដើម្បីត្រៀមសម្រាប់កិច្ចប្រជុំកំពូលលើកទី១៣ (13th CLV DTA JCC) នាពេលខាងមុខ អគ្គនាយកដ្ឋានកៅស៊ូបានពិនិត្យនិងធ្វើបច្ចុប្បន្នភាពលើខ្លឹមសារនិងតួលេខរបស់កម្ពុជាក្នុងឆ្នាំ២០២២ រួមមាន ផ្ទៃដីចម្ការកៅស៊ូ ទិន្នផល ផលិតផលសម្រេច ចំនួនរោងចក្រ/សិប្បកម្ម និងផលិតផលកែច្នៃ ដែលមានក្នុងផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV DTA) និងបានផ្ញើទៅក្រសួង នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣។

### ២.៦.១២ កិច្ចសហប្រតិបត្តិការជាមួយរោងចក្រកមន្តសាល

៩៨- **សហគ្រាសខាតថាយអឺរ ឯ.ក (CART TIRE Co., LTD)**

- កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ បានចុះអនុស្សារណៈយោគយល់គ្នា (MoU) ស្តីពី "កិច្ចសហការសម្របសម្រួលផ្គត់ផ្គង់ផលិតផលជ័រកៅស៊ូ" ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវខ្សែច្រវាក់នៃការផ្គត់ផ្គង់ផលិតផលកៅស៊ូធម្មជាតិនៅប្រទេសកម្ពុជាប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដោយផ្តោតលើយន្តការរួមមាន (១)សម្របសម្រួលនិងជំរុញឲ្យមានការផ្គត់ផ្គង់កៅស៊ូធម្មជាតិក្នុងស្រុករវាងអ្នកដាំកៅស៊ូ និងរោងចក្រកែច្នៃកម្មន្តសាល

ផលិតសំបកកង់យានយន្ត (២)សម្របសម្រួលបង្កើតឱកាសទីផ្សារក្នុងស្រុក សំដៅបង្កើនចំណូលដល់អ្នកដាំកៅស៊ូនិងសេដ្ឋកិច្ចជាតិ និង(៣)ជំរុញការប្រើប្រាស់កៅស៊ូក្នុងស្រុក និងចូលរួមគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥។ លទ្ធផលការងារមានដូចខាងក្រោម៖

- បានជួបពិភាក្សាអំពីវឌ្ឍនភាពខ្សែច្រវាក់ផលិតកម្មកែច្នៃសំបកកង់យានយន្ត និងត្រៀមរៀបចំទស្សនកិច្ចសិក្សាសហគ្រាសខាតថាយអឺរ ឯ.ក សម្រាប់អ្នកផ្គត់ផ្គង់កៅស៊ូធម្មជាតិ ជាពិសេសសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- បានចូលរួមវេទិកាអ្នកផ្គត់ផ្គង់និងអ្នកប្រាស់កៅស៊ូធម្មជាតិ ដើម្បីស្វែងយល់អំពី (១)តម្រូវការ-ការផ្គត់ផ្គង់ (២)លក្ខខណ្ឌតម្រូវស្តង់ដារផលិតផលកៅស៊ូសម្រាប់ជាវត្ថុធាតុដើមកែច្នៃសំបកកង់យានយន្ត (៣)បង្កើនជំនឿទុកចិត្តគ្នាក្នុងការធ្វើធុរកិច្ចកៅស៊ូទាំងបរិមាណនិងគុណភាព និង(៤)រៀបចំយន្តការនិងវិះរកដំណោះស្រាយបញ្ហាប្រឈមទីផ្សារនាពេលអនាគត។

៥៩- **កិច្ចសហប្រតិបត្តិការជាមួយរោងចក្រ RMKH Glove (Cambodia) Co., Ltd**

- បានជួបពិភាក្សានិងស្វែងយល់ពីខ្សែច្រវាក់ផលិតកម្មកែច្នៃស្រោមដៃ និងត្រៀមរៀបចំទស្សនកិច្ចសិក្សារោងចក្រ RMKH Glove (Cambodia) Co., Ltd សម្រាប់អ្នកផ្គត់ផ្គង់កៅស៊ូធម្មជាតិ ជាពិសេសសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- បានចូលរួមវេទិកាអ្នកផ្គត់ផ្គង់និងអ្នកប្រាស់កៅស៊ូធម្មជាតិកៅស៊ូ ដើម្បីស្វែងយល់អំពី (១)តម្រូវការ-ការផ្គត់ផ្គង់ (២)ស្ថានភាពកៅស៊ូធម្មជាតិនៅកម្ពុជា និង(៣)ការត្រៀមខ្លួនទទួលទិញផលិតផលជ័រកៅស៊ូធម្មជាតិ។

## ៣. បញ្ហាប្រឈម

៦០- ទន្ទឹមនឹងភាពរីកចម្រើន អនុវិស័យកៅស៊ូប្រឈមនឹងបញ្ហាមួយចំនួនដូចខាងក្រោម៖

- ខ្វះកម្លាំងពលកម្ម ជាពិសេសជំនាញចៀរជ័រ(ការប្រកួតប្រជែងពីវិស័យដទៃ)
- ផលិតភាពចម្ការកៅស៊ូនៅទាប
- គុណភាពផលិតផលកៅស៊ូរបស់កសិករនៅមានកម្រិតទាប
- កង្វះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួន
- ថ្លៃកៅស៊ូបន្តនៅទាប ធៀបនឹងថ្លៃដើមផលិត
- ការផ្តល់ថវិកាគាំទ្រនិងធនធានមនុស្សនៅមានកម្រិត
- ការផ្តល់និងការទទួលយកបច្ចេកវិទ្យាកៅស៊ូសមស្របសម្រាប់កសិករកៅស៊ូគ្រួសារ នៅមានកម្រិត
- យន្តការគាំទ្រសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅមានកម្រិត (កង្វះឥណទាន មណ្ឌលកែច្នៃកៅស៊ូ និងមជ្ឈមណ្ឌលទីផ្សារកៅស៊ូ ។ល។)
- ការផ្តល់របាយការណ៍អាជីវកម្ម ផលិតកម្មប្រចាំខែពីបណ្តាក្រុមហ៊ុនមួយចំនួននៅមានការយឺតយ៉ាវ
- ការនាំចេញកៅស៊ូរបស់ក្រុមហ៊ុនមួយចំនួន មិនបានបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់កៅស៊ូយថាប្រភេទកម្ពុជា(CSR)
- លទ្ធភាពនៃការប្រមូលព័ត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងកៅស៊ូធម្មជាតិនៅតែជាបញ្ហាប្រឈមនៅឡើយ
- កង្វះធនធានមនុស្សសម្រាប់ការសិក្សា ស្រាវជ្រាវ
- ការទទួលយកផលិតផលកៅស៊ូក្នុងស្រុកសម្រាប់ការកែច្នៃផលិតផលសម្រេចនៅមានកម្រិត។

## ៤. សន្និដ្ឋាន

៦១- ទោះបីមានការលំបាកដោយសារវិបត្តិសេដ្ឋកិច្ចសកល និងបញ្ហាប្រឈមផ្សេងទៀតយ៉ាងណាក៏ដោយ ប៉ុន្តែឈរលើស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុងរវាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំអស់ពីកម្លាំងកាយកម្លាំងចិត្ត ដោយមានការចូលរួមពីគ្រប់ប្រតិបត្តិករកៅស៊ូ និងការណែនាំពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិសេសពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រី ដែលជានិច្ចកាលតែងបានផ្តល់នូវអនុសាសន៍ល្អៗ និងការគាំទ្រទាំងស្មារតី ថវិកា និងបញ្ញាញាណ ទើបធ្វើឱ្យការអនុវត្តការងារកៅស៊ូ ទទួលបាននូវលទ្ធផលជាផ្លែផ្កានិងមានប្រសិទ្ធភាពខ្ពស់។

## ៥. ទិសដៅឆ្នាំ២០២៤

### ក. សូចនាករនិងចំណុចដៅ

៦២- ដើម្បីសម្រេចបាននូវទិសដៅ នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ក៏ដូចជាចូលរួមចំណែកសម្រេចបាននូវទិសដៅនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ ក្នុងការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្ម ការតម្រង់ទិសឆ្នាំ២០២៤ នៃអនុវិស័យកៅស៊ូ បានកំណត់នូវសូចនាករនិងចំណុចដៅសំខាន់ៗ ដូចខាងក្រោម៖

- ជំរុញបង្កើនផ្ទៃដីកៅស៊ូយកផល ឱ្យបានក្នុងរង្វង់៣២០,៥ពាន់ហិកតា (កើន០,១% ធៀបនឹងឆ្នាំ២០២៣)
- ជំរុញទិន្នផលកៅស៊ូ ឱ្យបានក្នុងរង្វង់១ ២២៩គីឡូក្រាម/ហិកតា/ឆ្នាំ (កើន០,៥% ធៀបនឹងឆ្នាំ២០២៣)
- ជំរុញបង្កើនផលិតផលកៅស៊ូឱ្យបានក្នុងរង្វង់៣៩៤ពាន់តោន (កើន០,៦% ធៀបនឹងឆ្នាំ២០២៣)
- ជំរុញការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកឱ្យបានក្នុងរង្វង់៤០ពាន់តោន (កើន៣១% ធៀបនឹងឆ្នាំ២០២៣)។

### ខ. ផែនការសកម្មភាព

៦៣- ដើម្បីសម្រេចសូចនាករនិងចំណុចដៅខាងលើ ការតម្រង់ទិសផែនការសកម្មភាពសំខាន់ត្រូវបានលើកឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

តារាងទី៦៖ ទិសដៅសកម្មភាពឆ្នាំ២០២៤

| សកម្មភាព | សូចនាករ | ឯកតា | ចំណុចដៅ |
|---|---|---|---|
| ជំរុញការប្រើប្រាស់ក្លូនកៅស៊ូដែលមានសក្តានុពល | ទំហំផ្ទៃដីច្បារពូជថ្មី | ហិកតា | ១ |
| ការអភិវឌ្ឍសហគមន៍កសិកម្មកៅស៊ូគ្រួសារ | ចំនួនសហគមន៍ | សហគមន៍ | ៥ |
| សិក្សាសមិទ្ធិលទ្ធភាពអាចធ្វើបាននូវការកែច្នៃកៅស៊ូសមាសឬកៅស៊ូចម្រុះ | ចំនួនឯកសារសិក្សា | ក្បាល | ១ |
| រៀបចំសៀវភៅគោលការណ៍ណែនាំបច្ចេកទេសកែច្នៃកៅស៊ូ | ចំនួនឯកសារសិក្សា | ក្បាល | ១ |
| ជំរុញប្រើប្រាស់កៅស៊ូធម្មជាតិក្នុងស្រុក | ចំនួនប្រជុំ | ដង | ៩ |
| គាំទ្រព័ត៌មានកៅស៊ូតាមប្រព័ន្ធអេឡិចត្រូនិច | ចំនួនប្រជុំ | ដង | ២ |

| សកម្មភាព | សូចនាករ | ឯកតា | ចំណុចដៅ |
|---|---|---|---|
| គាំទ្រដំណើរការរដ្ឋបាល | ចំនួនរបាយការណ៍ | របាយការណ៍ | ១ |
| កសាងឯកសារគោលនយោបាយនិងផែនការ | ចំនួនចុះតាមដាន | លើក | ១០ |
| តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ | ចំនួនចុះតាមដាន | លើក | ៥ |
| សិក្ខាសាលាស្ដីពីការវិវត្តកៅស៊ូធម្មជាតិ | ចំនួនសិក្ខាកាម | នាក់ | ៤០ |
| ជំរុញការប្រមូលចំណូល និងចុះបញ្ជីដីចម្ការកៅស៊ូ | អត្រាចំណូលត្រូវបានប្រមូល | ភាគរយ | ៩៥ |
| ពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីរាជការ | ចំនួនសិក្ខាកាម | នាក់ | ៨០ |
| រៀបចំសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត | ចំនួនលិខិតបទដ្ឋាន | ច្បាប់ | ១ |

## ៦. ទិសដៅឆ្នាំ២០២៥

ទស្សនទានក្នុងការអភិវឌ្ឍអនុវិស័យកៅស៊ូ គឺផ្ដោតលើការបង្កើនផលចំណេញដល់អ្នកផលិតកៅស៊ូ តាមរយៈយន្តការបង្កើនអាយុសេដ្ឋកិច្ចដើមកៅស៊ូ កាត់បន្ថយថ្លៃដើម និងបង្កើនតម្លៃបន្ថែម។

### ក. សូចនាករនិងទិសដៅ

៦៤- នៅឆ្នាំ២០២៥ សូចនាករនិងចំណុចដៅសំខាន់ៗ ដែលបានគ្រោង រួមមាន៖

- ជំរុញបង្កើនផ្ទៃដីកៅស៊ូយកផល ឱ្យបានក្នុងរង្វង់៣២៣,៥ពាន់ហិកតា (១% ធៀបនឹងឆ្នាំ២០២៣)
- ជំរុញទិន្នផលកៅស៊ូ ឱ្យបានក្នុងរង្វង់១ ២៣០គីឡូក្រាម/ហិកតា/ឆ្នាំ (០,៥% ធៀបនឹងឆ្នាំ២០២៣)
- ជំរុញបង្កើនផលិតផលកៅស៊ូឱ្យបានក្នុងរង្វង់៣៩៨ពាន់តោន (១,៦% ធៀបនឹងឆ្នាំ២០២៣)
- ជំរុញការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកឱ្យបានក្នុងរង្វង់៧២ពាន់តោន (កើន១៣៦%ធៀបនឹងឆ្នាំ២០២៣)។

### ខ. វិធានការ

៦៥- ដើម្បីសម្រេចទិសដៅដែលបានកំណត់ខាងលើ អគ្គនាយកដ្ឋានកៅស៊ូបានដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

- បន្តសិក្សា ស្រាវជ្រាវ និងកសាងលិខិតគតិយុត្តពាក់ព័ន្ធ
- បន្តអនុវត្តនិងតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- បន្តជំរុញការប្រើប្រាស់ក្លូនកៅស៊ូដែលមានសក្ដានុពល
- បន្តជំរុញការអភិវឌ្ឍសហគមន៍កសិកម្មកៅស៊ូគ្រួសារ ដើម្បីរួមគ្នាកាត់បន្ថយថ្លៃដើម និងបង្កើនអំណាចចរចា
- បន្តជំរុញនិងកែលម្អគុណភាពផលិតផលកៅស៊ូ តម្រូវតាមទីផ្សារ
- បន្តជំរុញការប្រើប្រាស់កៅស៊ូក្នុងស្រុក
- បន្តសម្របសម្រួលនិងពង្រឹងសកម្មភាពរបស់សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា (ARDC)
- បន្តជំរុញការសិក្សាលទ្ធភាពបង្កើតមជ្ឈមណ្ឌលកែច្នៃ និងទីផ្សារកៅស៊ូ

- បន្តជំរុញការប្រមូលចំណូល ឱ្យសម្រេចតាមចំណុចដៅ
- បន្តពិនិត្យតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តចុះពិនិត្យនិងផ្តល់ប្រឹក្សាផ្ទាល់នៅចម្ការជាមួយកសិករកៅស៊ូគ្រួសារ
- បន្តសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីពូជ បច្ចេកទេស ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- បន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានាក្នុងការបណ្តុះបណ្តាលធនធានមនុស្ស លើមុខវិជ្ជាបច្ចេកទេសដាំដុះ ការយកផលទឹកជ័រ សរីរសាស្ត្រទឹកជ័រ ជំងឺ និងកត្តាចង្រៃលើដំណាំកៅស៊ូ
- បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- បន្តអនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់ការនាំចេញកៅស៊ូនិងវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ
- បន្តចូលរួមសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានា
- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយ ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការជាតិនិងអន្តរជាតិនានា ដើម្បីគាំទ្រការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា។

## ៧. សំណូមពរ

៦៦- ឆ្លើយតបចំពោះបញ្ហាប្រឈមនិងតម្រូវការចាំបាច់ ក្នុងការអភិវឌ្ឍអនុវិស័យកៅស៊ូឱ្យទទួលបានជោគជ័យនិងមាននិរន្តរភាព អគ្គនាយកដ្ឋានកៅស៊ូ សូមលើកសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមផ្តល់មន្ត្រីក្របខណ្ឌជំនាញឱ្យបានសមស្រប
- សូមបង្កើនថវិកាតាមកម្មវិធី ដើម្បីអនុវត្តសកម្មភាពឱ្យសម្រេចបានតាមចំណុចដៅនៃសូចនាករ
- សូមគាំទ្រនិងជំរុញការកសាងលិខិតគតិយុត្តពាក់ព័ន្ធ
- សូមជួយសម្របសម្រួលនិងពង្រឹងសកម្មភាពរបស់សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា (ARDC) ដើម្បីជួយទ្រទ្រង់ដល់ការអភិវឌ្ឍអនុវិស័យកៅស៊ូ
- សូមជំរុញការផ្តល់របាយការណ៍អាជីវកម្ម ផលិតកម្មប្រចាំខែពីបណ្តាក្រុមហ៊ុនឱ្យបានទៀងទាត់
- សូមជំរុញការទទួលយកផលិតផលកៅស៊ូក្នុងស្រុកសម្រាប់ការកែច្នៃផលិតផលសម្រេច
- សូមជំរុញក្រុមហ៊ុននាំចេញកៅស៊ូ ត្រូវបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូយថាប្រភេទកម្ពុជា (CSR) នៅពេលនាំចេញកៅស៊ូ៕

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

# រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ

(យោងអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨)



**ឧបសម្ព័ន្ធទី២**

# របាយការណ៍ប្រមូលចំណូលថវិការដ្ឋឆ្នាំ២០២៣

| ល.រ | រាយមុខចំណូល | គ្រោង ឆ្នាំ២០២៣ | ទឹកប្រាក់បានបង់ ឆ្នាំ២០២៣ | ភាគរយ |
|---|---|---|---|---|
| 1 | | 2 | 3 | 4=3/2*100 |
| | **សរុបរួម** | 1,511,400,000 | 1,714,782,543 | 113.46 |
| **អនុគណនី** (73071) **ការជួលដីទំនេរ អវិនិយោគចំការកៅស៊ូទាំង៧** | | 1,153,200,000 | 1,159,382,426 | 100.54 |
| ១ | ចំការកៅស៊ូជុប | 354,400,000 | 355,954,645 | 100.44 |
| ២ | ចំការកៅស៊ូមេមត់ | 185,500,000 | 184,972,663 | 99.72 |
| ៣ | ចំការកៅស៊ូក្រែក | 131,900,000 | 133,498,673 | 101.21 |
| ៤ | ចំការកៅស៊ូស្នួល | 98,300,000 | 99,743,832 | 101.47 |
| ៥ | ចំការកៅស៊ូចំការអណ្តូង | 141,400,000 | 141,206,800 | 99.86 |
| ៦ | ចំការកៅស៊ូពាមជាំង | 112,500,000 | 114,014,144 | 101.35 |
| ៧ | ចំការកៅស៊ូបឹងកេត | 129,200,000 | 129,991,669 | 100.61 |
| **អនុគណនី** (73072) **ការជួលដីមានអគារ** | | 358,200,000 | 550,395,820 | 153.66 |
| ១ | ក្រុមហ៊ុននីហាវ័ណ អាហាវ័ណកៅស៊ូ | 98,800,000 | 8,339,016 | 101.10 |
| | | | 8,308,626 | |
| | | | 8,203,274 | |
| | | | 8,227,586 | |
| | | | 8,341,042 | |
| | | | 8,347,120 | |
| | | | 8,359,276 | |
| | | | 8,375,484 | |
| | | | 8,353,198 | |
| | | | 8,367,380 | |
| | | | 8,343,068 | |
| | | | 8,324,834 | |
| ២ | ចំការកៅស៊ូឡាបានសៀក | 259,400,000 | 450,505,916 | 173.67 |
| **អនុគណនី** (74012) **ការពិន័យ និងការដាក់ទណ្ឌកម្ម ពិន័យជាប្រាក់** | | | 1,997,797 | |
| ១ | ចំការកៅស៊ូស្នួល ឆ្នាំ២០២៣ | | 1,997,797 | |
| **អនុគណនី** (76981) **ផលហិរញ្ញវត្ថុផ្សេងៗទៀត** | | | 3,006,500 | |
| ១ | បង់សំណែសចំណាយបៀវត្សឆ្នាំ២០២២ | | 3,006,500 | |

**ឧបសម្ព័ន្ធទី៣**

# លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២៣

| ឈ្មោះចង្កោមសកម្មភាព | ថវិកា (លានរៀល) | | | លទ្ធផល | | | |
|---|---|---|---|---|---|---|---|
| | ច្បាប់ថវិកា | ចំណាយ | ភាគរយ | សូចនាករ | ចំណុចដៅ | សម្រេចបាន | ភាគរយ |
| **សរុបរួម** | 3,968.20 | 3,685.04 | 92.86 | | | | |
| **បន្ទុកបុគ្គលិក** | 2,875.40 | 2,650.75 | 92.19 | | | | |
| **ក្រៅបន្ទុកបុគ្គលិក** | 1,092.80 | 1,034.29 | 94.65 | | | | |
| **អនុកម្មវិធី ១.៥ ៖ ការជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិ** | **1,092.80** | **1,034.29** | **94.65** | ១.ផ្ទៃដីកៅស៊ូយកផល (ហិកតា) | **319,700** | **320,184** | **100.15** |
| | | | | ២.ផលិតផលកៅស៊ូ (តោន) | **390,000** | **391,800** | **100.46** |
| | | | | ៣.ការនាំចេញ (តោន) | **388,000** | **368,048** | **94.86** |
| ចង្កោមសកម្មភាពទី១.៥.១: ការជំរុញផលិតកម្មកៅស៊ូ | 185.90 | 183.76 | 98.85 | ទិន្នផលកៅស៊ូកើនឡើង (គ.ក្រ/ហ.ត) | 1,220 | 1,228 | 100.66 |
| ចង្កោមសកម្មភាព ១.៥.២៖ ការកែច្នៃនិងការពង្រឹងគុណភាពកៅស៊ូ | 29.70 | 29.70 | 99.99 | អត្រាគុណភាពកៅស៊ូល្អ (ភាគរយ) | 79 | 79.3 | 100.38 |
| ចង្កោមសកម្មភាព១.៥.៣៖ ការពង្រឹងយន្តការទីផ្សារកៅស៊ូ | 94.30 | 94.02 | 99.70 | អត្រាតម្លៃលក់ផលិតផលកៅស៊ូរបស់កសិករ/FOB (ភាគរយ) | 71 | 71 | 100.00 |
| ចង្កោមសកម្មភាពទី១.៥.៤៖ ការរៀបចំ ការអនុវត្តផែនការ និងការគ្រប់គ្រងថវិកា | 750.70 | 694.67 | 92.54 | អត្រាថវិកាត្រូវបានអនុវត្ត (ភាគរយ) | 95 | 92.86 | 97.75 |
| ចង្កោមសកម្មភាព១.៥.៥៖ ការកសាងក្របខណ្ឌគតិយុត្ត និងអភិវឌ្ឍន៍ធនធានមនុស្ស | 32.20 | 32.15 | 99.84 | ១.ចំនួនសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត (ច្បាប់) | 1 | 1 | 100.00 |
| | | | | ២.ចំនួនប្រតិបត្តិករកៅស៊ូ (នាក់) | 150 | 150 | 100.00 |

ឧបសម្ព័ន្ធទី៤

## គោលដៅនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២៤

| បរិយាយ | ថវិកាអនុម័ត (លានរៀល) | | | សូចនាករ | ចំណុចដៅ |
|---|---|---|---|---|---|
| | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | ភាគរយ | | |
| **សរុបរួម** | 3,968.20 | 3,909.70 | 98.53 | | |
| **បន្ទុកបុគ្គលិក** | 2,875.40 | 2,739.60 | 95.28 | | |
| **ក្រៅបន្ទុកបុគ្គលិក** | 1,092.80 | 1,170.10 | 107.07 | | |
| អនុកម្មវិធី ១.៤ ៖ លើកកម្ពស់និងពង្រីកខ្សែច្រវាក់តម្លៃកៅស៊ូ | 1 092.80 | 1 170.10 | 107.07 | ផលិតផលកៅស៊ូ (តោន) | **394,000** |
| ចង្កោមសកម្មភាព ១.៥.១៖ ការពង្រឹងប្រសិទ្ធភាពចម្ការកៅស៊ូ | 185.90 | 283.40 | 152.45 | ទំហំផ្ទៃដីច្បារពូជថ្មី (ហិកតា) | 1 |
| ចង្កោមសកម្មភាព ១.៥.២៖ ការកែច្នៃនិងការពង្រឹងគុណភាពកៅស៊ូ | 29.70 | 17.50 | 58.92 | ចំនួនឯកសារសិក្សា (ក្បាល) | 2 |
| ចង្កោមសកម្មភាព១.៥.៣៖ ការពង្រឹងយន្តការទីផ្សារកៅស៊ូ | 94.30 | 59.70 | 63.31 | ចំនួនប្រតិបត្តករចូលរួម (នាក់) | 340 |
| ចង្កោមសកម្មភាព១.៥.៤៖ ការរៀបចំការអនុវត្តផែនការ និងការគ្រប់គ្រងថវិកា | 750.70 | 792.80 | 105.61 | អត្រាថវិកាត្រូវបានអនុវត្ត (ភាគរយ) | 96 |
| ចង្កោមសកម្មភាព១.៥.៥៖ ការកសាងក្របខណ្ឌគតិយុត្តនិងអភិវឌ្ឍន៍ធនធានមនុស្ស | 32.20 | 16.70 | 51.86 | ចំនួនសិក្ខាកាម (នាក់) | 80 |

**ឧបសម្ព័ន្ធទី៥**

# ស្ថិតិដំណាំកៅស៊ូកម្ពុជាឆ្នាំ២០២៣

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដី(ហ.ត) | | ផ្ទៃដីកៅស៊ូ(ហ.ត) | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | កិច្ចសន្យា | ចុះបញ្ជី | យកផល | ថែទាំ | សរុប | |
| I | **ចម្ការកៅស៊ូកសិឧស្សាហកម្ម** | | **635,496** | **377,500** | **164,184** | **62,656** | **226,840** | |
| | **ក-អតីតចម្ការកៅស៊ូរដ្ឋនិងវសកក** | **ខេត្ត** | **71,586** | **61,182** | **33,260** | **13,422** | **46,682** | |
| 1 | សុភក្តិនីកា អ៊ិនវេសមេន គ្រុប (ជុប) | ត្បូងឃ្មុំ+ក.ធំ | 17,401 | 17,405 | 10,470 | 2,427 | 12,897 | |
| 2 | អាន ម៉ាឌី គ្រុប(ពាមជាំង) | ត្បូងឃ្មុំ | 3,947 | 3,947 | 1,856 | 1,041 | 2,897 | |
| 3 | ក្រែក(ខេមបូឌា) ខូអិលធីឌី(ក្រែក) | ត្បូងឃ្មុំ | 14,231 | 5,116 | 3,657 | 715 | 4,372 | |
| 4 | ចម្ការកៅស៊ូមេមត់ | ត្បូងឃ្មុំ | 9,121 | 8,732 | 5,245 | 3,176 | 8,421 | |
| 5 | ចម្ការកៅស៊ូ តាប៉ាវ | ត្បូងឃ្មុំ | 3,244 | 3,244 | 1,436 | 797 | 2,233 | |
| 6 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ត្បូងឃ្មុំ | 1,033 | 1,033 | 754 | 81 | 835 | |
| 7 | អាន ម៉ាឌី គ្រុប(ចម្ការអណ្តូង) | កំពង់ចាម | 6,956 | 6,956 | 1,999 | 2,853 | 4,852.00 | |
| 8 | ឡុងស្រេងអ៊ិនធឺណេសិនណល (បឹងកេត) | កំពង់ចាម | 7,314 | 6,353 | 3,117 | - | 3,117 | |
| 9 | ស៊ីហ្វរីសសស៍លីមីធីត(ស្នួល) | ក្រចេះ | 4,824 | 4,807 | 4,174 | 159 | 4,333 | |
| 10 | ស៊ីហ្វវ៉ាប់ប៊ើរលីមីធីត(ឡាបានសៀក) | រតនគិរី | 3,517 | 3,589 | 552 | 2,172 | 2,724 | |
| | **ខ-ចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច** | **ខេត្ត** | **563,910** | **316,318** | **130,924** | **49,234** | **180,158** | **ក្រុមហ៊ុន** |
| 1 | សុភក្តិនីកាអ៊ីនវេសមេនអាក្រូអ៊ិនដាសស្រៀលផ្លេនខូអិលធីឌី | ស្ទឹងត្រែង | 10,000 | | 1,361 | 1,766 | 3,127.00 | ខ្មែរ |
| 2 | សល សុភា ពាណិជ្ជ ខូ អិលធីឌី | ស្ទឹងត្រែង | 9,917 | | 1,300 | 2,330 | 3,630.00 | ខ្មែរ |
| 3 | ម្កុដ ពេជ្រ អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | 1,950 | 1,846 | 150 | 350 | 500.00 | ខ្មែរ |
| 4 | កៅស៊ូ អេលៃវ ប៊ីអឹម យ៉ញស្កុក ខូ អិលធីឌី | រតនគិរី | 8,400 | 1,425 | 659 | 625 | 1,284.49 | វៀតណាម |
| 5 | ហ៊ង អាន ម៉ាង យ៉ាង ខេ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | រតនគិរី | 6,891 | 6,102 | 5,372 | 313 | 5,685.47 | វៀតណាម |
| 6 | គីរី អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | 807 | 661 | 623 | 12 | 635.21 | វៀតណាម |
| 7 | ក្រុង ប៊ុក រតនគិរី អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | រតនគិរី | 6,695 | 6,052 | 5,621 | - | 5,621.00 | វៀតណាម |
| 8 | ហេង ប្រាឌ័រ ខូ អិលធីឌី | រតនគិរី | 2,361 | 1,961 | 783 | 204 | 986.89 | វៀតណាម |
| 9 | ស៊ី អ ឌី ខូ អិលធីឌី | រតនគិរី | 7,591 | 3,284 | 847 | 285 | 1,132.00 | វៀតណាម |
| 10 | ហ៊ង អាន អូរយ៉ាដាវ ខូ អិលធីឌី | រតនគិរី | 9,000 | 3,129 | 648 | 289 | 936.50 | វៀតណាម |
| 11 | វ៉ាសនា អ៊ិនវេសមេន | រតនគិរី | 5,080 | 1,764 | 1,107 | 435 | 1,541.92 | វៀតណាម |
| 12 | ជាំងលី (អ៊ិនវេសមេន) ខូ អិលធីឌី | រតនគិរី | 1,900 | 200 | | 174 | 174.00 | ខ្មែរ |
| 13 | ឌី អឹម គ្រុប ខូអិលធីឌី | រតនគិរី | 749 | 185 | 184 | - | 184.00 | ខ្មែរ |
| 14 | ៧ មករា ផារី ខូ អិលធីឌី (ហេងអភិវឌ្ឍន៍) | រតនគិរី | 8,654 | 1,244 | | 40 | 40.00 | ខ្មែរ |
| 15 | នុភាព សុភី អ៊ិនវេសមេន ខូ អិលធីឌី | រតនគិរី | 9,000 | 8,577 | | 60 | 60.00 | ខ្មែរ |
| 16 | មិត្តភាព ម៉ែន សារុន ខូ អិលធីឌី | រតនគិរី | 6,324 | 1,300 | 576 | 416 | 991.54 | វៀតណាម |
| 17 | ជា ច័ន្ទរិទ្ធ អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | 5,124 | 914 | 588 | 165 | 752.94 | វៀតណាម |
| 18 | ផេស៊ីហ្វិក ឡូធើស យ៉ញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,014 | 8,984 | - | 745 | 744.97 | វៀតណាម |
| 19 | ផេស៊ីហ្វិក ភើល យ៉ញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,614 | 9,508 | - | 1,565 | 1,565.34 | វៀតណាម |
| 20 | ផេស៊ីហ្វិក ប្រាយដ៏ យ៉ញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,773 | 9,646 | - | 3,518 | 3,518.07 | វៀតណាម |
| 21 | ផេស៊ីហ្វិក ប្រេ្គន យ៉ញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,956 | 9,654 | - | 453 | 453.10 | វៀតណាម |
| 22 | ឌី ធី ស៊ី គ្រុប ខូ អិលធីឌី | មណ្ឌលគិរី | 5,704 | 3,813 | 138 | 7 | 145.35 | ខ្មែរ |
| 23 | កូវីផាម៉ា ខូ អិលធីឌី | មណ្ឌលគិរី | 5,345 | 3,738 | 2,202 | 1,025 | 3,227.00 | បារាំង |
| 24 | សេដ្ឋីកូលា | មណ្ឌលគិរី | 4,273 | | 1,884 | - | 1,884.00 | បារាំង |
| 25 | ខេ ភីស អ៊ិនវេសមេន (ខេមបូឌា) ខូ អិលធីឌី | មណ្ឌលគិរី | 500.00 | | | 110 | 110.00 | ខ្មែរ |
| 26 | វ៉ារ៉ាណាស៊ី | មណ្ឌលគិរី | 2,705 | | 1,778 | 30 | 1,808.00 | បារាំង |
| 27 | ដាក់ ឡាក់ មណ្ឌលគិរី អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | មណ្ឌលគិរី | 4,162 | 1,498 | 1,421 | - | 1,420.60 | វៀតណាម |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដី (ហ.ត) | | ផ្ទៃដីកៅស៊ូ (ហ.ត) | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | កិច្ចសន្យា | ចុះបញ្ជី | យកផល | ថៃទាំ | សរុប | |
| I | **ចម្ការកៅស៊ូកសិឧស្សាហកម្ម** | | **635,496** | **377,500** | **164,184** | **62,656** | **226,840** | |
| | **ខ-ចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច** | **ខេត្ត** | **563,910** | **316,318** | **130,924** | **49,234** | **180,158** | **ក្រុមហ៊ុន** |
| 28 | វី ឡា ឌីវេឡុបមេន ខូ អិលធីឌី | មណ្ឌលគិរី | 728 | 722 | 310 | - | 310.00 | ខ្មែរ |
| 29 | ប៊ិញហ្វឿក ក្រចេះរ៉ាប់ប៊ើរ១ ខមភេនី លីមីធីត | មណ្ឌលគិរី | 8,926 | 4,291 | 3,451 | - | 3,451.30 | វៀតណាម |
| 30 | ដុងភូ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (៣គំរោង) | ក្រចេះ | 8,470 | 5,875 | 5,132 | 15 | 5,147.29 | វៀតណាម |
| 31 | ដុងណាយ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (២គំរោង) | ក្រចេះ | 7,085 | 6,523 | 4,944 | - | 4,944.29 | វៀតណាម |
| 32 | ញូ ឡាញ ខេម ភីធីវ៉ាយ អិលធីឌី | ក្រចេះ | 8,977 | 8,461 | 627 | 276 | 903.00 | អូស្រ្តាលី |
| 33 | អេហ្វ្រី អ៊ិនដាសស្រ្ទៀល ក្រប ឌីវេឡុបមេន (ខេមបូឌា) ខូ អិល | ក្រចេះ | 7,000 | | - | 580 | 580.00 | ចិន |
| 34 | ក្រប & លែន ឌីវេឡុបមែន (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | 7,200 | | - | 425 | 425.00 | ចិន |
| 35 | ស៊ុន គុយ ទី អ៊ីមផត & អ៊ិចផត | ក្រចេះ | 903 | | | 75 | 75.00 | ខ្មែរ |
| 36 | ហ្វ្រិន អាយលែន អេហ្វ្រីខលឈើវ័ល ឌីវេឡុបមេន ខូ អិលធីឌី | ក្រចេះ | 9,583 | 8,181 | - | 1,367 | 1,367.00 | ចិន |
| 37 | ស៊ី អេច ភី ប៊ី ឌីវេឡុបមេន ខូ អិលធីឌី | ក្រចេះ | 8,686 | | | 369 | 369.00 | ខ្មែរ |
| 38 | ឈុន ហុង រ៉ាប់ប៊ើរ បេតធើរ ខូ អិលធីឌី | ក្រចេះ | 8,202 | 7,764 | 763 | 2,878 | 3,641.00 | ចិន |
| 39 | ភូរៀង ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (២គំរោង) | ក្រចេះ | 5,647 | 5,647 | | 418 | 418.02 | អង្លេស |
| 40 | ដូវទីសាយហ្គន- ប៊ីញហ្វឿក (អេស ប៊ី ខេ) ខូ អិលធីឌី | ក្រចេះ | 6,592 | 2,715 | 628 | 1,083 | 1,711.30 | អង្លេស |
| 41 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ (ស្វាយជ្រះ) | ក្រចេះ | 994 | 882 | 244 | 227 | 471.00 | អង្លេស |
| 42 | ដូវទៀង ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាក្រា | ក្រចេះ | 6,592 | 2,060 | 1,973 | 22 | 1,995.00 | វៀតណាម |
| 43 | ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដា | ក្រចេះ | 7,972 | 2,550 | 2,059 | 203 | 2,262.22 | វៀតណាម |
| 44 | ច័ន្ទ សុភា អភិវឌ្ឍន៍ ខូ អិលធីឌី | ក្រចេះ | 5,088 | 718 | 207 | 305 | 512.03 | ខ្មែរ |
| 45 | សុវណ្ណ វុទ្ធី ខូ អិលធីឌី | ក្រចេះ | 5,000 | 1,219 | 1,009 | 159 | 1,167.62 | វៀតណាម |
| 46 | ប៊ីញហ្វឿក ក្រចេះ រ៉ាប់ប៊ើរ ២ ខមភេនី លីមីធីត | ក្រចេះ | 10,000 | 4,740 | 722 | 280 | 1,002.00 | វៀតណាម |
| 47 | អ៊ីសធើន រ៉ាប់ប៊ើរ (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | 5,000 | 4,749 | 1,046 | 271 | 1,317.00 | វៀតណាម |
| 48 | សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី | ក្រចេះ | 1,225 | | 876 | - | 876.00 | ខ្មែរ |
| 49 | ត្រាចញៀម ហ៊ូហាន ដូវទី-ហ្វាតទ្រៀន ដាយណាម-កម្ពុជា | ក្រចេះ | 2,616 | 2,248 | 504 | 1,035 | 1,539.39 | វៀតណាម |
| 50 | E-Investment (Cambodia) Ltd | ក្រចេះ | 6,450 | 5,828 | 650 | 2,173 | 2,823.00 | ខ្មែរ |
| 51 | ចម្ការកៅស៊ូ មេមត់ ខូ អិលធីឌី | ក្រចេះ | 9,855 | 4,335 | 487 | 1,118 | 1,604.77 | ខ្មែរ |
| 52 | វៀតណាម កម្ពុជា Economy Trade and Industry | ក្រចេះ | 5,059 | 4,381 | 3,833 | - | 3,833.00 | វៀតណាម |
| 53 | សាយឌុង កៅស៊ូ ឌុកឌុង ខូ អិលធីឌី | ក្រចេះ | 1,852 | 1,621 | 979 | 520 | 1,499.28 | វៀតណាម |
| 54 | សុវណ្ណរាជសីហ៍ ខូ អិលធីឌី | ក្រចេះ | 6,525 | 2,867 | 1,150 | 900 | 2,050.00 | វៀតណាម |
| 55 | ថេរវិនិយោគ | ក្រចេះ | 520 | | | 269 | 269.00 | ខ្មែរ |
| 56 | ជី ភី អ៊ី | ក្រចេះ | 678 | | | 227 | 227.00 | ខ្មែរ |
| 57 | រតនៈស្ដោន ខេមបូឌា ខូ អិលធីឌី | ក្រចេះ | 479 | | | 242 | 242.00 | ខ្មែរ |
| 58 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ (ធ្នូ) | ក្រចេះ | 609 | 557 | - | 40 | 39.50 | ខ្មែរ |
| 59 | ខេមបូ ហា យ៉ុង វិនិយោគ កសិ-ឧស្សាហកម្ម | ក្រចេះ | 701 | | | 91 | 91.00 | ខ្មែរ |
| 60 | ធី ធី វ៉ាយ | ក្រចេះ | 9,780 | | | 135 | 135.00 | ខ្មែរ |
| 61 | ប៊ីធីម៉ិចកូ សុធី អភិវឌ្ឍន៍ ខូ អិលធីឌី | ត្បូងឃ្មុំ | 980 | 959 | | 225 | 225.00 | ខ្មែរ |
| 62 | ហេង ឆៃអឹម អភិវឌ្ឍន៍ ខូ អិលធីឌី | ត្បូងឃ្មុំ | 600 | 577 | | 225 | 225.00 | ខ្មែរ |
| 63 | ហេង សុខងន់ វិនិយោគ ខូ អិលធីឌី | ត្បូងឃ្មុំ | 833 | 531 | | 80 | 80.00 | ខ្មែរ |
| 64 | ម៉ែន សារុន អាហារ័ណ នីហរ័ណ | ត្បូងឃ្មុំ | 4,400 | 1,135 | | 185 | 185.00 | ខ្មែរ |
| 65 | ប៊ី អិន អេ (ខេម) ខប | កំពង់ធំ | 7,500 | 3,060 | - | 355 | 354.91 | កូរ៉េ |
| 66 | ខេមបូឌា ហ្វាម័រ អ៊ីនវេសមេន ខូ អិលធីឌី | កំពង់ធំ | 938 | | | 95 | 95.00 | ខ្មែរ |
| 67 | ឫទ្ធិមុនី សំណាងលាភ ខូ អិលធីឌី | កំពង់ធំ | 1,745 | 1,678 | 1,623 | - | 1,623.00 | ខ្មែរ |
| 68 | ហ្គោល ហ្វ៊យសុន (ខេមបូឌា) អេ/ស៊ី អ៊ីមផត អ៊ិចផត & ខនស្រ្ទ | កំពង់ធំ | 7,000 | 3,221 | 1,506 | 862 | 2,368.00 | វៀតណាម |
| 69 | ស៊ី ស៊ី វី ខូ អិលធីឌី | កំពង់ធំ | 5,730 | 2,014 | 774 | 540 | 1,314.00 | វៀតណាម |
| 70 | តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 8,100 | 7,767 | 7,244 | - | 7,243.91 | វៀតណាម |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដី ( ហ.ត ) | | ផ្ទៃដីកៅស៊ូ ( ហ.ត ) | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | កិច្ចសន្យា | ចុះបញ្ជី | យកជល | ថៃទាំ | សរុប | |
| I | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | 635,496 | 377,500 | 164,184 | 62,656 | 226,840 | |
| ខ-ចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច | | ខេត្ត | 563,910 | 316,318 | 130,924 | 49,234 | 180,158 | ក្រុមហ៊ុន |
| 71 | បារ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 5,914 | 5,292 | 5,394 | - | 5,393.65 | វៀតណាម |
| 72 | តឿក វ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 9,784 | 8,694 | 7,664 | - | 7,664.00 | វៀតណាម |
| 73 | ទេពី អាគ្រូ វិនិយោគ ខូ អិលធីឌី | កំពង់ធំ | 1,000 | 926 | 850 | - | 850.00 | ខ្មែរ |
| 74 | សម្បត្តិ ផ្លែធីណឹម ខូ អិលធីឌី | កំពង់ធំ | 2,496 | 1,982 | 1,429 | 151 | 1,580.00 | ខ្មែរ |
| 75 | ស៊ី អ ស៊ី ខេ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 6,044 | 5,272 | 4,107 | 110 | 4,216.86 | វៀតណាម |
| 76 | សាម ម៉េង អាហារ៍ណ នីហារ៍ណ | កំពង់ធំ | 225 | 224 | 224 | - | 224.00 | ខ្មែរ |
| 77 | រតនៈខេម អាហ្គ្រោ អ៊ិនដាសស្ទ្រៀល អិលធីឌី | កំពង់ធំ | 900 | 812 | 807 | - | 807.00 | ខ្មែរ |
| 78 | ទ្រីភាព អ៊ីមផត អ៊ិចផត | កំពង់ធំ | 600 | | 340 | - | 340.00 | ខ្មែរ |
| 79 | កុល វាសនា អិនវេសមេន ខូ អិលធីឌី | កំពង់ធំ | 9,863 | 6,198 | 395 | 1,006 | 1,401.48 | ខ្មែរ |
| 80 | កៅស៊ូ មេគង្គ ខូ អិលធីឌី | កំពង់ធំ | 9,235 | 6,081 | 5,714 | - | 5,714.00 | វៀតណាម |
| 81 | អាន ម៉ាឌី គ្រុប ខូ អិលធីឌី | កំពង់ធំ | 9,993 | | - | 800 | 800.00 | ខ្មែរ |
| 82 | ប៉ោ ខួច អភិវឌ្ឍន៍ ខូ អិលធីឌី | កំពង់ធំ | 350 | 306 | | 10 | 10.00 | ខ្មែរ |
| 83 | ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | កំពង់ធំ | 9,235 | 8,553 | 8,236 | - | 8,236.23 | វៀតណាម |
| 84 | បៀន ហៀក អិនវេសមេន ខូ អិលធីឌី | កំពង់ធំ | 9,480 | 8,653 | 8,032 | - | 8,032.45 | វៀតណាម |
| 85 | រាម ណា វិនិយោគ ខូ អិលធីឌី | ព្រះវិហារ | 410 | 25 | | 27 | 27.00 | ខ្មែរ |
| 86 | ធីង៉ា អភិវឌ្ឍន៍ និងវិនិយោគ ខូ អិលធីឌី | ព្រះវិហារ | 6,060 | 6,060 | | 100 | 100.00 | វៀតណាម |
| 87 | ឬទ្ធី ក្រានីត (ខេមបូឌា) ខូ អិលធីឌី | ព្រះវិហារ | 1,646 | 1,646 | 1,546 | - | 1,546.00 | វៀតណាម |
| 88 | ទ្រីភាព អ៊ីមផត អ៊ិចផត | ព្រះវិហារ | 9,916 | 4,800 | 3,925 | 1,727 | 5,652.00 | ខ្មែរ |
| 89 | សុវណ្ណភូមិ វិនិយោគ កសិ-ឧស្សាហកម្ម | ព្រះវិហារ | 9,913 | 7,479 | 500 | 1,270 | 1,770.00 | ខ្មែរ |
| 90 | ហ្វ្រីន ឌីវេឡុបមេន ខូ អិលធីឌី | ព្រះវិហារ | 984 | 969 | - | 129 | 129.00 | ខ្មែរ |
| 91 | សីលាដាម៉ិច ខូ អិលធីឌី | ព្រះវិហារ | 9,000 | 6,378 | - | 187 | 187.00 | ខ្មែរ |
| 92 | តែនិញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | ឧត្តរមានជ័យ | 7,600 | 4,161 | 3,692 | 133 | 3,824.98 | វៀតណាម |
| 93 | បេស រ៉ូយ៉ាល់ (ខេ) ខូ អិលធីឌី | ឧត្តរមានជ័យ | 6,500 | 3,943 | 1,587 | 1,808 | 3,395.00 | វៀតណាម |
| 94 | សុខ សំណាង ឌីវេឡុបមេន ខូ អិលធីឌី | ឧត្តរមានជ័យ | 1,865 | 1,756 | 350 | 161 | 511.00 | ខ្មែរ |
| 95 | ដាតា រ៉ាប់ប៊ើរ (ខេមបូឌា) ខូ អិលធីឌី | ឧត្តរមានជ័យ | 7,700 | | - | 26 | 26.00 | ខ្មែរ |
| 96 | ទុមរីង រ៉ាប់ប៊ើរ ខូ អិលធីឌី | ឧត្តរមានជ័យ | 7,750 | 387 | 272 | 82 | 354.00 | ចិន |
| 97 | ហួត ម៉េងរីតា ខូ អិលធីឌី | ឧត្តរមានជ័យ | 4,195 | 1,030 | 435 | 725 | 1,160.00 | ខ្មែរ |
| 98 | សំរោង រ៉ាប់ប៊ើរ អ៊ិនដាសស្ទ្រៀល ភី ធី អ៊ី អិលធីឌី | ឧត្តរមានជ័យ | 9,658 | 7,720 | 2,272 | 1,342 | 3,614.31 | ខ្មែរ |
| 99 | Green Rubber Development Plantation co.,LTD | សៀមរាប | 6,000 | 1,458 | | 220 | 220.00 | ម៉ាឡេស៊ី |
| 100 | ខេន លីមីធីត | សៀមរាប | 4,535 | 1,672 | 1,253 | 228 | 1,481.00 | ខ្មែរ |
| 101 | MDS (ទ្រី ភាព) | ពោធិ៍សាត់ | 6,352 | 4,338 | 700 | 2,300 | 3,000.00 | ខ្មែរ |
| 102 | ស៊ី អិន អេស៊ាន អេសហ្វ្រី ខលឈ័រ | កោះកុង | 4,100 | 4,094 | 1,216 | 1,271 | 2,487.51 | ថៃ |
| 103 | កោះកុង រ៉ាប់ប៊ើរ ផ្លេនថេសិន ខូ អិលធីឌី | កោះកុង | 9,977 | 9,727 | - | 1,953 | 1,952.69 | ថៃ |
| 104 | លឹម លុង ខូ អិលធីឌី (LIM LONG Co.,Ltd) | កោះកុង | 321 | 321 | | 280 | 280.00 | ខ្មែរ |
| II | ចម្ការកៅស៊ូគ្រួសារ ( ៣៤ ៥៥២គ្រួសារ ) | ខេត្ត | - | | 156,000 | 24,332 | 180,332.00 | |
| 1 | មាន១៩ ២២០គ្រួសារ | ត្បូងឃ្មុំ | | | 44,200 | 11,729 | 55,929 | |
| 2 | មាន២ ៤០៥គ្រួសារ | រតនគិរី | | | 37,807 | 213 | 38,020 | |
| 3 | មាន៣ ០៦៣គ្រួសារ | កំពង់ចាម | | | 20,744 | 840 | 21,584 | |
| 4 | មាន៣ ៨៤២គ្រួសារ | ក្រចេះ | | | 13,230 | 4,901 | 18,131 | |
| 5 | មាន១ ៧១៨គ្រួសារ | មណ្ឌលគិរី | | | 11,130 | 740 | 11,870 | |
| 6 | មាន ៨៦៨គ្រួសារ | កំពង់ធំ | | | 6,717 | 2,462 | 9,179 | |
| 7 | មាន ៧៧៤គ្រួសារ | ស្ទឹងត្រែង | | | 4,686 | 1,274 | 5,960 | |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដី (ហ.ត) | | ផ្ទៃដីកៅស៊ូ (ហ.ត) | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | កិច្ចសន្យា | ចុះបញ្ជី | យកផល | ថែទាំ | សរុប | |
| II | **ចម្ការកៅស៊ូគ្រួសារ (៣៤ ៥៥២គ្រួសារ)** | **ខេត្ត** | **-** | | **156,000** | **24,332** | **180,332.00** | |
| 8 | មាន ៤៦៣ គ្រួសារ | ព្រះវិហារ | | | 3,050 | 480 | 3,530 | |
| 9 | មាន ២០៦ គ្រួសារ | បាត់ដំបង | | | 2,091 | - | 2,091 | |
| 10 | មាន ១១៩គ្រួសារ | ឧត្តរមានជ័យ | | | 1,799 | 39 | 1,838 | |
| 11 | មាន១៦៤ គ្រួសារ | ប៉ៃលិន | | | 1,481 | 558 | 2,039 | |
| 12 | មាន ២០៩គ្រួសារ | កោះកុង | | | 1,669 | - | 1,669 | |
| 13 | មាន ៦៤គ្រួសារ | ព្រះសីហនុ | | | 822 | - | 822 | |
| 14 | មាន ៦០គ្រួសារ | សៀមរាប | | | 1,381 | - | 1,381 | |
| 15 | មាន ១២គ្រួសារ | បន្ទាយមានជ័យ | | | 170 | - | 170 | |
| 16 | មាន ២៨៥គ្រួសារ | ស្វាយរៀង | | | 1,683 | 989 | 2,672 | |
| 17 | មាន ១៤គ្រួសារ | កំពង់ស្ពឺ | | | 536 | - | 536 | |
| 18 | មាន ៣១៥គ្រួសារ | ពោធិ៍សាត់ | | | 905 | - | 905 | |
| 19 | មាន ៧២៨គ្រួសារ | ព្រៃវែង | | | 1,458 | 107 | 1,565 | |
| 20 | មាន ២៣គ្រួសារ | កំពត | | | 441 | - | 441 | |
| **សរុប (I+II)** | | | **635,496** | **377,500** | **320,184** | **86,988** | **407,172** | |

| ល.រ | ប្រភេទចម្ការកៅស៊ូ | ចំនួន | ផ្ទៃដី (ហ.ត) | | ផ្ទៃដីកៅស៊ូ (ហ.ត) | | | % |
|---|---|---|---|---|---|---|---|---|
| | | | កិច្ចសន្យា | ចុះបញ្ជី | យកផល | ថែទាំ | សរុប | |
| I | **ចម្ការកៅស៊ូកសិឧស្សាហកម្ម** | 114 | **635,496** | **377,500** | **164,184** | **62,656** | **226,840** | **56** |
| | ក-អតីតចម្ការកៅស៊ូរដ្ឋនិងវសកក | 10 | 71,586 | 61,182 | 33,260 | 13,422 | **46,682** | 11 |
| | ខ-ចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច | 104 | 563,910 | 316,318 | 130,924 | 49,234 | **180,158** | 44 |
| II | **ចម្ការកៅស៊ូគ្រួសារ (៣៤ ៥៥២គ្រួសារ)** | **20ខេត្ត** | **0** | | **156,000** | **24,332** | **180,332** | **44** |
| **សរុបរួម I +II** | | | **635,496** | **377,500** | **320,184** | **86,988** | **407,172** | **100** |

**ឧបសម្ព័ន្ធទី៦**

## ស្ថិតិផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(វសកក) ឆ្នាំ២០២៣

| ឈ្មោះ / ឆ្នាំ | សុភក្តិនីកា | | អានម៉ាឌី គ្រុប | ក្រែក(ខេមបូឌា) | មេមត់ | តាប៉ាវ | វសកក | អានម៉ាឌី គ្រុប | ឡុង ស្រេង | ស៊ីសវ៉េសល | ស៊ីសរ៉ាប់បើរ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជុប | ទំរីង | ពាមជាំង | ក្រែក | | | | ចម្ការអណ្ដូង | បឹងកេត | ស្នួល(ក្រចេះ) | រតនគិរី | |
| 1994 | | | | - | | 63 | | | | | | 63 |
| 1995 | - | | | - | | 50 | | | | | | 50 |
| 1996 | - | | | - | | 51 | | | | | | 51 |
| 1997 | - | | | - | | 28 | | | | | | 28 |
| 1998 | - | | | - | | 45 | | | | 24 | | 68 |
| 1999 | - | | | | | 5 | | | | 61 | | 66 |
| 2000 | - | | | | | - | | 28 | | 22 | | 50 |
| 2001 | - | - | | 65 | | - | | 347 | | 92 | 79 | 582 |
| 2002 | 432 | 360 | | | | - | 216 | 182 | | 44 | | 1,233 |
| 2003 | 758 | 492 | | 131 | | - | 36 | 34 | | 100 | | 1,551 |
| 2004 | 1,042 | 471 | | 305 | 153 | 263 | 49 | 212 | | 337 | | 2,832 |
| 2005 | 910 | 581 | 186 | 518 | 160 | 234 | 48 | 354 | | 452 | | 3,441 |
| 2006 | 1,002 | 171 | 205 | 347 | 134 | 246 | 78 | - | | 218 | | 2,402 |
| 2007 | 984 | 26 | 242 | 437 | - | 298 | 101 | - | | 183 | | 2,270 |
| 2008 | 719 | - | 177 | 527 | 709 | 213 | 75 | 1,277 | 1,082 | 26 | | 4,804 |
| 2009 | 441 | 42 | 72 | 507 | 519 | | 61 | 818 | 484 | 956 | 129 | 4,028 |
| 2010 | 478 | 191 | 171 | 373 | 862 | - | 31 | 528 | 857 | 1,133 | 34 | 4,657 |
| 2011 | 743 | 136 | 260 | 280 | 1,158 | - | 13 | 12 | 215 | 472 | 291 | 3,580 |
| 2012 | 490 | - | 271 | | 1,005 | 70 | 13 | 442 | 202 | 55 | 501 | 3,048 |
| 2013 | | - | 176 | 22 | 678 | 175 | 19 | 29 | 209 | | 671 | 1,979 |
| 2014 | - | - | 349 | | 118 | 172 | 13 | 591 | 69 | | 438 | 1,749 |
| 2015 | - | - | 204 | 137 | 34 | 54 | 26 | | | | 355 | 811 |
| 2016 | - | - | | | - | | | | | 15 | 60 | 75 |
| 2017 | 145 | - | 204 | | 396 | 50 | | | | | 109 | 903 |
| 2018 | 548 | - | | | 294 | 50 | 24 | | | | | 917 |
| 2019 | 317 | - | | | 466 | 50 | 34 | | | | 58 | 925 |
| 2020 | 49 | - | 14 | | 351 | 75 | | | | 106 | | 595 |
| 2021 | 387 | - | 46 | | 476 | 44 | | | | 38 | | 991 |
| 2022 | 393 | | 137 | 400 | 491 | | | | | | | 1,422 |
| 2023 | 481 | 106 | 183 | 325 | 417 | | | | | | | 1,512 |
| **សរុបរួម** | **12,897** | | **2,897** | **4,372** | **8,421** | **2,233** | **835** | **4,852** | **3,117** | **4,333** | **2,724** | **46,682** |

ឧបសម្ព័ន្ធទី៧

# តារាងផ្ទៃដីដាំដុះកៅស៊ូតាមឆ្នាំនីមួយៗគិតត្រឹមឆ្នាំ២០២៣ (ហិកតា)

| ល.រ | ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ខេត្ត | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | សុភក្តិនីកា អ៊ីនវេសមេន អាគ្រូ អ៊ិនដាសស្ទ្រៀល ផ្លេន ខូ អិលធីឌី | ស្ទឹងត្រែង | 163 | 301 | 623 | 379 | 707 | 235 | 20 | 96 | 336 | 178 | 89 | | | | | | | 3,127.00 |
| 2 | សល សុភា ពាណិជ្ជ ខូ អិលធីឌី | ស្ទឹងត្រែង | 415 | 720 | 650 | | | 640 | 620 | 585 | | | | | | | | | | 3,630.00 |
| 3 | ម្កុដ ពេជ្រ អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | | | | | | | | | | 500 | | | | | | | | 500.00 |
| 4 | កៅស៊ូ អេលែរ ប៊ីអឹម យ៉ាញស្គុក ខូ អិលធីឌី | រតនគិរី | | | | | | 510 | 765 | 9 | | | | | | | | | | 1,284.49 |
| 5 | ហ៊ាង អាន ម៉ាង យ៉ាង ខេ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | រតនគិរី | | | | 701 | 1752 | 1428 | 1735 | 69 | | | | | | | | | | 5,685.47 |
| 6 | គីរី អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | | | | | 43 | 144 | 447 | | | | | | | | | | | 635.21 |
| 7 | ក្រុង ប៊ុក រតនគិរី អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | រតនគិរី | | | | 235 | 1404 | 1540 | 2110 | 305 | 28 | | | | | | | | | 5,621.00 |
| 8 | ហេង ប្រាឌំ ខូ អិលធីឌី | រតនគិរី | | | | 383 | 328 | 277 | | | | | | | | | | | | 986.89 |
| 9 | ស៊ី អ ឌី ខូ អិលធីឌី | រតនគិរី | | | | | 89 | 578 | 465 | | | | | | | | | | | 1,132.00 |
| 10 | ហ៊ាង អាន អូយ៉ាដាវ ខូ អិលធីឌី | រតនគិរី | | | | | | | 547 | 389.92 | | | | | | | | | | 936.50 |
| 11 | វាសនា អ៊ិនវេសមេន | រតនគិរី | | | | | 283 | 568 | 691 | | | | | | | | | | | 1,541.92 |
| 12 | ជាំងលី (អ៊ិនវេសមេន) ខូ អិលធីឌី | រតនគិរី | | | | | | 40 | 90 | | 44.00 | | | | | | | | | 174.00 |
| 13 | ឌី អឹម គ្រុប ខូអិលធីឌី | រតនគិរី | | | | | | 115 | 69 | | | | | | | | | | | 184.00 |
| 14 | ៧ មករា ផារី ខូ អិលធីឌី (ហេងអភិវឌ្ឍន៍) | រតនគិរី | | | | 40 | | | | | | | | | | | | | | 40.00 |
| 15 | នុភាព សុភី អ៊ិនវេសមេន ខូ អិលធីឌី | រតនគិរី | | | | | | | | | 60 | | | | | | | | | 60.00 |
| 16 | មិត្តភាព ម៉ែន សារុន ខូ អិលធីឌី | រតនគិរី | | | | | | 585 | 250 | 157 | | | | | | | | | | 991.54 |
| 17 | ជា ច័ន្ទរិទ្ធ អភិវឌ្ឍន៍ ខូ អិលធីឌី | រតនគិរី | | | | | | 200 | 290 | 263 | | | | | | | | | | 752.94 |
| 18 | ផេស៊ីហ្វិក ឡូធើស យ៉ាញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | | | | | | 13 | 104 | 571 | 56.26 | | | | | | | | | 744.97 |
| 19 | ផេស៊ីហ្វិក ភើល យ៉ាញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | | | | | | 426 | 312 | 804 | | 24 | | | | | | | | 1,565.34 |
| 20 | ផេស៊ីហ្វិក ប្រាយដ៏ យ៉ាញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | | | | | | 542 | 707 | 1056 | 983 | 230 | | | | | | | | 3,518.07 |
| 21 | ផេស៊ីហ្វិក ហ្គ្រេន យ៉ាញ-ស្កុក ខមភេនី លីមីធីត | មណ្ឌលគិរី | | | | | | | 403 | 50 | | | | | | | | | | 453.10 |
| 22 | ឌី ធី ស៊ី គ្រុប ខូ អិលធីឌី | មណ្ឌលគិរី | | | | | | | 145 | | | | | | | | | | | 145.35 |
| 23 | កូវីផាម៉ា ខូ អិលធីឌី | មណ្ឌលគិរី | | | 18 | 288 | 247 | 446 | 426 | 1065 | 737 | | | | | | | | | 3,227.00 |
| 24 | សេដ្ឋីកូលា | មណ្ឌលគិរី | | | | 634 | 950 | 300 | | | | | | | | | | | | 1,884.00 |
| 25 | ខេ ភីស អ៊ិនវេសមេន (ខេមបូឌា) ខូ អិលធីឌី | មណ្ឌលគិរី | | | 110 | | | | | | | | | | | | | | | 110.00 |
| 26 | វ៉ាវ៉ាណាស៊ី | មណ្ឌលគិរី | | | 580 | 590 | 638 | | | | | | | | | | | | | 1,808.00 |
| 27 | ដាក់ ឡាក់ មណ្ឌលគិរី អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី | មណ្ឌលគិរី | | 45 | 193 | 750 | 433 | | | | | | | | | | | | | 1,420.60 |
| 28 | វី ឡា ឌីវេឡុបមេន ខូ អិលធីឌី | មណ្ឌលគិរី | | | | | | | 310.00 | | | | | | | | | | | 310.00 |

| ល.រ | ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ខេត្ត | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 29 | ប៊ិញហ្វឿក ក្រចេះរ៉ាប់ប៊ើរ១ ខមភេនី លីមីធីត | មណ្ឌលគិរី | | | | | | 23 | 1039 | 1255 | 1134 | | | | | | | | | 3,451.30 |
| 30 | ដុងភូ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (៣គំរោង) | ក្រចេះ | | 72 | 974 | 1665 | 1415 | 773 | 215 | 21 | 13 | | | | | | | | | 5,147.29 |
| 31 | ដុងណាយ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (២គំរោង) | ក្រចេះ | | 295 | 1269 | 970 | 2410 | | | | | | | | | | | | | 4,944.29 |
| 32 | ញូ ឡាញ ខេម ភីធីវ៉ាយ អិលធីឌី | ក្រចេះ | | | | | | 207.00 | 314.00 | 305.00 | | 37.00 | | | 40.00 | | | | | 903.00 |
| 33 | អេហ្គ្រី អ៊ិនដាសស្ទ្រៀល គ្រុប ឌីវេឡុបមេន (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | | | | | | 500 | | 80 | | | | | | | | | | 580.00 |
| 34 | គ្រុប & លែន ឌីវេឡុបមែន (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | | | | | | 300 | | 125 | | | | | | | | | | 425.00 |
| 35 | ស៊ិន គុយ ទី អ៊ីមផត & អិចផត | ក្រចេះ | | | | | | 75 | | | | | | | | | | | | 75.00 |
| 36 | ហ្គ្រិន អាយលែន អេហ្គ្រីខលឈើរ៉ល ឌីវេឡុបមេន ខូ អិលធីឌី | ក្រចេះ | | | | | | | 843 | 500 | 24 | | | | | | | | | 1,367.00 |
| 37 | ស៊ី អេច ភី ប៊ី ឌីវេឡុបមេន ខូ អិលធីឌី | ក្រចេះ | | | | | | 243 | 78 | 47 | | | | | | | | | | 369.00 |
| 38 | ឈុន ហុង រ៉ាប់ប៊ើរ បេតធើរ ខូ អិលធីឌី | ក្រចេះ | | | | | 139 | 699 | 473 | 1644 | 130 | | | 557 | | | | | | 3,641.00 |
| 39 | ភូរៀង ក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ អិលធីឌី (២គំរោង) | ក្រចេះ | | 171 | 235.35 | 11.94 | | | | | | | | | | | | | | 418.02 |
| 40 | ដូវទីសាយហ្គន- ប៊ិញហ្វឿក (អេស ប៊ី ខេ) ខូ អិលធីឌី | ក្រចេះ | | | | | | | 784 | 790 | 69 | 69 | | | | | | | | 1,711.30 |
| 41 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ (ស្វាយជ្រះ) | ក្រចេះ | | | 160 | | | | | | 209 | 102 | | | | | | | | 471.00 |
| 42 | ដូវទៀង ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាក្រាវខូ) | ក្រចេះ | | | | | 20 | 608 | 930 | 150 | 286 | | | | | | | | | 1,995.00 |
| 43 | ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ) | ក្រចេះ | | | | | 20 | 725 | 662 | 449 | 90 | 316 | | | | | | | | 2,262.22 |
| 44 | ច័ន្ទ សុភា អភិវឌ្ឍន៍ ខូ អិលធីឌី | ក្រចេះ | | | | | 50 | 122 | 42 | 148 | 100 | 6 | | 20 | 2 | 23 | | | | 512.03 |
| 45 | សុវណ្ណ វុទ្ធី ខូ អិលធីឌី | ក្រចេះ | | | | | 251 | 881 | 15 | 21 | | | | | | | | | | 1,167.62 |
| 46 | ប៊ិញហ្វឿក ក្រចេះ រ៉ាប់ប៊ើរ ២ ខមភេនី លីមីធីត | ក្រចេះ | | | | | | | 830 | 172 | 0 | | | | | | | | | 1,002.00 |
| 47 | អ៊ីសធើន រ៉ាប់ប៊ើរ (ខេមបូឌា) ខូ អិលធីឌី | ក្រចេះ | | | | | | 388 | 305 | 624 | 0 | | | | | | | | | 1,317.00 |
| 48 | សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី | ក្រចេះ | | | | 300 | 300 | 276 | | | | | | | | | | | | 876.00 |
| 49 | ត្រាចញៀម ហ៊ូហាន ដូវទី-ហ្វាតទ្រៀន ដាយណាម-កម្ពុជា | ក្រចេះ | | | | | 196 | 508 | 528 | 197 | 95 | | 16 | | | | | | | 1,539.39 |
| 50 | E-Investment (Cambodia) Ltd | ក្រចេះ | | | | | 52 | 823 | 850 | 322 | | | | | | 176 | 100 | 500 | | 2,823.00 |
| 51 | ចម្ការកៅស៊ូ មេមត់ ខូ អិលធីឌី | ក្រចេះ | | | | | | | 152 | 206 | 232 | 239 | 0 | 136 | 13 | 8 | 109 | 268 | 242 | 1,604.77 |
| 52 | វៀតណាម កម្ពុជា Economy Trade and Industry | ក្រចេះ | | | | | 244 | 1202 | 2222 | 165 | | | | | | | | | | 3,833.00 |
| 53 | សាយខុង កៅស៊ូ ឧកខុង ខូ អិលធីឌី | ក្រចេះ | | | | 80 | 235 | 164 | 150 | 628 | 243 | | | | | | | | | 1,499.28 |
| 54 | សុវណ្ណរាជសីហ៍ ខូ អិលធីឌី | ក្រចេះ | | | | | 560 | 400 | 200 | 600 | 290 | | | | | | | | | 2,050.00 |
| 55 | ថេវវិនិយោគ | ក្រចេះ | | | 128 | 141 | | | | | | | | | | | | | | 269.00 |
| 56 | ជី ភី អ៊ី | ក្រចេះ | | | 40 | 90 | 97 | | | | | | | | | | | | | 227.00 |
| 57 | រតនៈស្តេាន ខេមបូឌា ខូ អិលធីឌី | ក្រចេះ | | | | 242 | | | | | | | | | | | | | | 242.00 |
| 58 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ (ធ្នូ) | ក្រចេះ | | | 30 | 10 | | | | | | | | | | | | | | 39.50 |
